# មាតិកា

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម


១- រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម....!!

២- ពិធីប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅអនុវត្ត របស់គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ស.ទ.ប.ក) និងក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) ....១

៣- សិក្ខាសាលាស្តីពីការរៀបចំផែនការសកម្មភាព សម្រាប់ការអនុវត្តសេចក្តីប្រកាសអាស៊ានលើការពង្រឹងការគាំពារសង្គម នៅខេត្តសៀមរាប ....៣

៤- សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីរបាយការណ៍នៃប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ....៤

៥- លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម លើកទី១៧ អាណត្តិទី៣ ....៥

៧- *កិច្ចប្រជុំកែសម្រួល និងពិនិត្យលើសេចក្តីព្រាងប្រកាស ស្តីពីសមាសភាព និង ការប្រព្រឹត្តទៅរបស់ គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស* ....៦

៨- វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពផ្ទៃក្នុងលើជំនាញពិគ្រោះយោបល់ ភាពជាអ្នកដឹកនាំ និងទ្រឹស្តីសង្គមវិទ្យាដល់មន្ត្រី ប.ស.ស ....៧

៩- ប្រជុំពិគ្រោះយោបល់សាធារណៈ ស្តីពីការកំណត់តាវកាលិកផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិត ....៨

១០- វគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណកម្មករនិយោជិត ....៩១

១- វគ្គបណ្តុះបណ្តាល ស្តីពីវិជ្ជាសង្គ្រោះបឋម....១០

១២- ដំណើរទស្សនកិច្ចសិក្សារបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ទៅប្រទេសអាឡឺម៉ង់ ....១១

១៣- សន្និសីទអន្តរជាតិ ស្តីពីកិច្ចគាំពារសង្គមឆ្នាំ២០១៤ នៅប្រទេសម៉ាឡេស៊ី ....១២

១៤- សិក្ខាសាលា ស្តីពីរបបធានារ៉ាប់រងសង្គម និងវេទិការពិភាក្សាស្តីពីកិច្ចគាំពារសង្គម នៅប្រទេសបង់ក្លាដេស ....១៣

១៥- លទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមការងារ ស.ផ.ក លើការពិនិត្យកែសម្រួលខ្លឹមសារវីដេអូអប់រំ (ស្កុត) ស្តីពីវិជ្ជាសង្គ្រោះបឋម....១៤

១៦- លទ្ធលនៃកិច្ចប្រជុំរបស់ក្រុមការងារ ស.ផ.ក លើការរៀបចំខ្សែវីដេអូអប់រំខ្លី សម្រាប់ធ្វើការផ្សព្វផ្សាយ ....១៥

១៧- ក្រុមការងារ ស.ទ.ប.ក ចុះពិនិត្យករណីកម្មករនិយោជិតសន្លប់ នៅរោងចក្រ SUNBEST ....១៦

១៨- កម្មករនិយោជិតសន្លប់បណ្តាលមកពីផ្សែងហុយចូលអាគារចង្វាក់ផលិតកម្ម នៅរោងចក្រ JTH Textile (CAMBODIA) ....១៧

១៩- ករណីកម្មការិនីសន្លប់ នៅរោងចក្រ Great Union (Cambodia) Garmant Co.,Ltd ដោយសារធំក្លិនប្រេងម៉ាស៊ីន និងក្លិនផ្សែងដុតសំរាមនៅក្បែរអាគារចង្វាក់ផលិតកម្ម ....១៨

២០- ប.ស.ស បានផ្សព្វផ្សាយគោលនយោបាយថ្មីៗ ដល់នាយក ម្ចាស់សហគ្រាស គ្រឹះស្ថាន នៅខេត្តប៉ៃលិន ....១៩

២១- គួរយល់ដឹងពីការទទួលទានអាហារដែលមានអត្ថប្រយោជន៍ដល់សុខភាព ....២០

២២- ទស្សនគួរពិចារណា ....២១

២៣- សេចក្តីជូនដំណឹង ស្តីពីនីតិវិធីនៃការបង់ភាគទានថ្មី ....២២

២៤- របៀបបង់ភាគទានសម្រាប់បេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស (តាមប្រព័ន្ធយូនីធីថ្មី) ....២៣

២៥- ក្រុមប្រចាំការ HOTLINE 24 ម៉ោង....២៦

២៦- អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត ....២៧

២៧- លេខទូរស័ព្ទទំនាក់ទំនងតាមមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ....២៩






## រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស

លោក អ៊ុក សមវិទ្យា នាយក ប.ស.ស

ចាងហ្វាង លោក ជាវ ប៊ុនរិទ្ធ

និពន្ធនាយក លោក ឌួង ច័ន្ទតារា

និពន្ធនាយករង លោក ចាយ សំណាង
លោក ស្រី សៅ

លេខានិពន្ធ លោកស្រី សុខ សូរ្យស្មី
កញ្ញា យ៉េម ចន្ធូ

ផ្នែកកុំព្យូទ័រ លោក យុន វិចិត្រ
លោក ពៅ សុវណ្ណារ៉ា

# រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម



# ប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅអនុវត្ត របស់គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ស.ទ.ប.គ) និងក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.គ)




ឯកឧត្តម សេង សក្តា អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃប.ស.ស អញ្ជើញជាអធិបតីក្នុងពិធីប្រជុំ



លោក អ៊ុក សមវិទ្យា នាយក ប.ស.ស អញ្ជើញឡើងផ្តល់របាយការណ៍ការងារក្នុងអង្គពិធី

ដើម្បីប្រតិបត្តិការការងារទទួលបានជោគជ័យ ល្គឹកណាតែយើងក្តាប់ឱ្យណែននូវទិន្នន័យជាក់លាក់ណាមួយ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការវាស់ស្ទង់ វាយតម្លៃ ទាញរកមូលហេតុ និងកំណត់បាននូវចំណុចប្រឈមដែលទាមទារឱ្យមានការដោះស្រាយ សម្រាប់ទប់ស្កាត់ និងបង្ការឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។

កត្តាគួរឱ្យកត់សម្គាល់ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ នៅសាលប្រជុំធំ ប.ស.ស មានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារសម្រេចបាន របស់គណៈកម្មការទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ និងក្រុមសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៥ ក្រោមអធិបតីភាព **ឯកឧត្តម សេង សក្តា** អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ **លោក អ៊ុក សមវិទ្យា** នាយក ប.ស.ស និងសមាជិករបស់គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ, ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត និងផ្នែកពាក់ព័ន្ធ តំណាងនិយោជក សហព័ន្ធសហជីព សហជីពមូលដ្ឋានជាច្រើនរូបទៀត។ ក្នុងឱកាសនោះ **លោក អ៊ុក សមវិទ្យា** នាយក



ឯកឧត្តម សេង សក្កា អញ្ជើញឡើងមានចំណាប់អារម្មណ៍ក្នុងកិច្ចប្រជុំ

ប.ស.ស បានជម្រាបជូនអង្គប្រជុំនូវរបាយការណ៍ដែលទាក់ទងទៅនឹងការអនុវត្តការងារក្នុងឆ្នាំកន្លងមក ទទួលបានលទ្ធផលល្អគួរជាទីមោទនៈ ដែលទន្ទឹមនឹងនោះក៏យើងត្រូវកំណត់ទិន្នន័យ ឬតួលេខឱ្យបានជាក់លាក់ ដើម្បីធ្វើការសន្និដ្ឋានរួម និងវែកញែកទាញរកហេតុផលនានា ធ្វើការវាស់ស្ទង់ និងវាយតម្លៃទៅលើលទ្ធផលដែលសម្រេចបាន ក្នុងការបង្កើតឱ្យចេញជាគោលការណ៍រួមសម្រាប់ធ្វើការទប់ស្កាត់ និងបង្ការនូវផ្នែកទាំងពីរនេះ(១) ដែលជាផ្នែកមួយមានហេតុផលរួមគ្នា និងត្រូវបានចាត់ទុកថាជាគ្រោះថ្នាក់ការងារ ដែលតម្រូវឱ្យធ្វើការទប់ស្កាត់ និងបង្ការហានិភ័យទាំងនេះឱ្យនៅកម្រិតទាបបំផុត ដែលអាចទៅបាន និងកំណត់ទិសដៅឱ្យបានច្បាស់ ដើម្បីអនុវត្តបន្តទទួលឱ្យបានលទ្ធផលល្អបន្ថែមទៀត។ បន្ទាប់ពីឱកាសដ៏ល្អនោះ **ឯកឧត្តម សេង សក្កា** អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ បានមានប្រសាសន៍គាំទ្រ និងកោតសរសើរ ដល់ក្រុមការងារទាំងអស់ដែលបានប្រតិបត្តិការការងាររបស់ខ្លួនកន្លងមកមានការខិតខំប្រឹងប្រែង និងមានការទទួលខុសត្រូវខ្ពស់។ ឯកឧត្តមបានផ្តាំផ្ញើ ដល់ក្រុមការងារឱ្យបង្កើនការ អនុវត្តភារកិច្ចរបស់ខ្លួនឱ្យទទួលបានលទ្ធផលល្អបន្ថែមទៀតដើម្បីបម្រើសេវាសាធារណៈជូនដល់កម្មករនិយោជិត។

ផ្អែកតាមផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដោយទទួលបានការណែនាំពីឯកឧត្តមរដ្ឋមន្ត្រី ដែលតម្រូវឱ្យ ប.ស.ស បង្កើនការផ្សព្វផ្សាយជាសាធារណៈ គ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ផ្នែកពាក់ព័ន្ធជាពិសេសជូនដល់កម្មករនិយោជិត។ ក្រសួងក៏ដូចជាអង្គភាព ប.ស.ស ដែលជាសេនាធិការផ្ទាល់ បានបង្កើតឱ្យមានគណៈកម្មការ និងក្រុមការងារ ដើម្បីធ្វើការប្រជុំ និងផ្សព្វផ្សាយអំពីការទប់ស្កាត់ និងបង្ការនូវគ្រោះថ្នាក់ការងារដែលកើតឡើងជាយថាហេតុឱ្យស្ថិតនៅកម្រិតមួយជាអប្បបរមា៕



ទិដ្ឋភាពចូលរួមរបស់សិក្ខាកាមក្នុងអង្គពិធី

# សិក្ខាសាលាស្តីពីការរៀបចំផែនការសកម្មភាព សម្រាប់ការអនុវត្តសេចក្តីប្រកាស អាស៊ានលើការពង្រឹងការគាំពារសង្គម នៅខេត្តសៀមរាប




ការចូលរួមសិក្ខាសាលារបស់បណ្តាប្រទេស ជាសមាជិកអាស៊ាន និងអង្គការជាតិ, អន្តរជាតិ នៅខេត្តសៀមរាប

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចាត់មន្ត្រីរបស់ខ្លួន លោក ម៉េង ហុង នាយករង ប.ស.ស និងមន្ត្រីមួយចំនួនទៀតចូលរួមសិក្ខាសាលាអន្តរវិស័យ ស្តីពីការរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តសេចក្តីប្រកាសអាស៊ានលើការពង្រឹងការគាំពារសង្គម នាថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០១៤ នៅខេត្តសៀមរាប ដែលរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមការឧបត្ថម្ភពីអង្គការ ILO, UNICEF, FAO, WHO, និងរដ្ឋាភិបាលជប៉ុនតាមរយៈលេខាធិការអាស៊ាន។ សិក្ខាសាលាបានប្រព្រឹត្តិទៅក្រោមអធិបតីភាព ឯកឧត្តម ងី ចាន់ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កសិកម្ម និងជនបទ និងអញ្ជើញចូលរួមបិទក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិត យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងមានការចូលរួមពីតំណាងរដ្ឋាភិបាល តំណាងអង្គការដែលបានឧបត្ថម្ភក្នុងអង្គសិក្ខាសាលា សមាគមនិយោជក និងតំណាងកម្មករនិយោជិតនៃបណ្តាប្រទេសអាស៊ានផងដែរ។ ក្នុងឱកាសនោះ គ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ បានធ្វើបទបង្ហាញរៀងៗខ្លួនដោយផ្តោតសំខាន់ទៅលើចក្ខុវិស័យ គោលដៅ គោលបំណង និងគោលការណ៍រួមផ្សេងៗ ដើម្បីធ្វើការពិគ្រោះយោបល់, ផ្លាស់ប្តូរបទពិសោធន៍ គ្នាទៅវិញទៅមក ដែលជាធាតុរួមមួយក្នុងការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តសេចក្តីប្រកាសអាស៊ានលើការពង្រឹងការគាំពារសង្គម និងដើម្បីឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋកម្ពុជាទាំងមូល។ សិក្ខាសាលាអន្តរវិស័យ ស្តីពីការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តសេចក្តីប្រកាសអាស៊ាន លើការពង្រឹងការគាំពារសង្គម បានបញ្ចប់ដោយភាពស្និទ្ធស្នាល និងមានការទទួលខុសត្រូវខ្ពស់៕






ការពិភាក្សាជាក្រុមរបស់មន្ត្រី ប.ស.ស និងសិក្ខាកាមដែលចូលរួមក្នុងអង្គសិក្ខាសាលា

# សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីរបាយការណ៍នៃប្រព័ន្ធព័ត៌មាន ជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក




ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន អញ្ជើញជាអធិបតីក្នុងអង្គសិក្ខាសាលា



យើងសង្កេតឃើញថា គ្រោះថ្នាក់ចរាចរណ៍ នៅកម្ពុជាសព្វថ្ងៃកើតឡើងគ្រប់សណ្ឋាន និងគ្រប់ប្រភេទ ដែលជាបញ្ហាមួយគួរឱ្យចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងរយៈពេលកន្លងមកនេះ។ គ្រោះថ្នាក់ចរាចរណ៍ជាឃាតកលាក់មុខ ដែលធ្វើឱ្យមនុស្សរាប់សិបនាក់រងរបួស និងស្លាប់យ៉ាងអាណោចអាធ័ម។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងស្ថាប័ន/អង្គភាពពាក់ព័ន្ធ បានយកចិត្តទុកដាក់ក្នុងការប្រជុំផ្សព្វផ្សាយអប់រំណែនាំទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យនៅកម្រិតទាបបំផុត។




ដោយឡែកនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា គណៈកម្មការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានរៀបចំបើកសិក្ខាសាលាផ្សព្វផ្សាយជាផ្លូវការ ស្តីពីប្រព័ន្ធព័តិមានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកសម្រាប់ឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ក្រសួង ស្ថាប័ន/អង្គភាពពាក់ព័ន្ធ និងមានមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលតំណាងឱ្យក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតផងដែរ។ ក្នុងឱកាសដ៏ថ្លៃថ្លានោះ ឯកឧត្តមរដ្ឋមន្ត្រី បានគូសបង្ហាញយ៉ាងច្បាស់អំពីទិន្នន័យ នៃករណីគ្រោះថ្នាក់ចរាចរណ៍ដូចខាងក្រោម៖

- ឆ្នាំ២០១៣ គ្រោះថ្នាក់ចរាចរណ៍មាន៤.៣៥៣ ករណី ជនរងគ្រោះសរុប១៦.២២៧នាក់ ស្លាប់១.៩៥០នាក់ និងរបួសធ្ងន់៥.៣៤៩នាក់ (ស្លាប់ច្រើនជាង៥នាក់ និងរបួសធ្ងន់១៦នាក់/ថ្ងៃ) បើប្រៀបធៀបឆ្នាំ២០១២ អ្នកស្លាប់មានការថយចុះ ប៉ុន្តែអ្នករងរបួសមានការកើនឡើង
- មូលហេតុចម្បង គឺបើកបរហួសល្បឿនកំណត់ និងក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង
- គ្រោះថ្នាក់ភាគច្រើននៅពេលយប់ (ចន្លោះពីម៉ោង៦ ដល់ម៉ោង៨យប់) និងពេលមានពិធីបុណ្យទានធំៗ ហើយជាយុវវ័យ និង មនុស្សពេញវ័យ
- ម៉ូតូ គឺជាយានដែលបានប្រើប្រាស់ច្រើនបំផុត និងងាយគ្រោះថ្នាក់បំផុត ក្នុងប្រទេសកម្ពុជា
- គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកនឹងបន្តផ្សព្វផ្សាយសង្កត់ធ្ងន់លើបញ្ហាល្បឿន។

អង្គសិក្ខាសាលាមានគោលបំណងធ្វើការវាស់ស្ទង់នូវកម្រិតករណីគ្រោះថ្នាក់ និងស្ថិតិនៃជនរងគ្រោះ ដើម្បីធ្វើការប្រជុំផ្សព្វផ្សាយអប់រំណែនាំដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទឱ្យគោរពច្បាប់ចរាចរណ៍ ក្នុងការកាត់បន្ថយគ្រោះថ្នាក់ជាយថាហេតុនេះឱ្យនៅកម្រិតមួយជាអប្បបរមា៕

# លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃបេឡាជាតិ របបសន្តិសុខសង្គម លើកទី ១៧ អាណត្តិទី៣

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកិច្ចដំណើរការរបស់ខ្លួន ដោយទទួលបានជោគជ័យជាបណ្តើរៗ និងបានចងក្រងជាច្បាប់ គតិយុត្តិនានា ឆ្លងកាត់ការប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការសម្រេចជាឯកច្ឆន្ទ ក្នុងការអភិវឌ្ឍន៍វិស័យរបស់ខ្លួនឱ្យមានតម្លាភាព ភាពរលូន និងមានប្រសិទ្ធភាពខ្ពស់។ ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម បានបង្កើតឡើងជាត្រីភាគីក្នុងនោះមានតំណាងរាជរដ្ឋាភិបាល តំណាងនិយោជក និងតំណាងកម្មករនិយោជិត។ ក្នុងរយៈពេលដាក់ឱ្យដំណើរការវិស័យសន្តិសុខសង្គមកន្លងមកនេះ ក្រុមប្រឹក្សាភិបាល នៃប.ស.ស បានបើកកិច្ចដំណើរការរបស់ខ្លួនបានជាច្រើនលើក ដោយធ្វើការអនុម័តនូវបទដ្ឋានគតិយុត្តិផ្សេងៗជាច្រើនទាក់ទងនឹងរបបហានិភ័យការងារ និងរបបផ្សេងៗទៀត ដែលបានគ្រោងដាក់ឱ្យដំណើរការនាពេលឆាប់ៗខាងមុខនេះ៕



ទិដ្ឋភាពប្រជុំពិភាក្សា ដើម្បីអនុម័តបទដ្ឋានគតិយុត្តិផ្សេងៗ





ការធ្វើបទបង្ហាញ ដើម្បីស្វែងរកចំណុចប្រឈម និងធ្វើការដោះស្រាយ ក្នុងកិច្ចប្រជុំ

# កិច្ចប្រជុំកែសម្រួល និងពិនិត្យលើសេចក្ដីព្រាងប្រកាស ស្ដីពីសមាសភាព និងការប្រព្រឹត្តទៅរបស់ គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹងនៃ ប.ស.ស



លោក ម៉េង ហុង នាយករង ប.ស.ស និងអ្នកជំនាញពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

ការដោះស្រាយជម្លោះជាបញ្ហាសំខាន់ ដើម្បីធ្វើឱ្យភាគីម្ខាងៗ មានការស្រុះស្រួលគ្នាតាមផ្លូវច្បាប់ណាមួយ។ ដូច្នេះដើម្បីមាន មូលដ្ឋានគ្រប់គ្រាន់ក្នុងការដោះស្រាយឱ្យមានតម្លាភាព។ គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹង នៃបេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥



ទិដ្ឋភាពនៃកិច្ចពិភាក្សាទាញរកមូលហេតុ និងធ្វើការដោះស្រាយរបស់គណៈកម្មការ

លើសេចក្ដីព្រាង នៃប្រកាសលេខ១៧៧ កប/ប្រ.ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្ដីពីសមាសភាព និងការប្រព្រឹត្ត ទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹង នៃបេឡាជាតិរបបសន្តិសង្គម ក្រោមការដឹកនាំដោយ លោក ម៉េង ហុង ប្រធានគណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹង នៃប.ស.ស និងមានសមាសភាពចូលរួមចំនួន ៧នាក់ទៀតរួមមាន តំណាងភាគីរាជរដ្ឋាភិបាល តំណាងភាគីនិយោជក និងតំណាងភាគីកម្មករនិយោជិត។

ក្រោយពីបានប្រជុំពិភាក្សាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេចយល់ព្រមជាឯកច្ឆន្ទ លើសេចក្ដីព្រាង នៃប្រកាសលេខ ១៧៧ កប/ប្រ.ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្ដីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹង នៃប.ស.ស។ ដោយលុបរង្វង់ក្រចក, បន្ថែមសញ្ញាខណ្ឌ នៅត្រង់ចុងបញ្ចប់ឃ្លានីមួយៗ និងកែសម្រួលឃ្លាទៅជា "តំណាងភាគីរាជរដ្ឋាភិបាល" នៃប្រការ៣ថ្មី និងបានសម្រេចលើសេចក្ដីព្រាង នៃសេចក្ដីសម្រេច ស្ដីពីការកំណត់បែបបទ និងរបៀបរបបការងាររបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹង នៃប.ស.ស អង្គប្រជុំបានសម្រេចយល់ព្រមជាឯកច្ឆន្ទ លើសេចក្ដីព្រាង នៃសេចក្ដីសម្រេច ដោយប្ដូរផ្នែកខាងលើមូលបទទៅជា "នាយកបេឡាជាតិរបបសន្តិសុខសង្គម" និងកែសម្រួលឃ្លាត្រង់កន្លែងទទួលទៅជា "គ្រប់សាខា ប.ស.ស រាជធានី/ខេត្ត"៕

# វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពផ្ទៃក្នុង លើជំនាញពិគ្រោះយោបល់ ភាពជាអ្នកដឹកនាំ និងទ្រឹស្តីសង្គមវិទ្យា ដល់មន្ត្រី ប.ស.ស



លោក អ៊ុក សមវិទ្យា នាយក ប.ស.ស មានមតិណែនាំដល់មន្ត្រីក្រោមឱវាទ

អញ្ជើញសាស្ត្រាចារ្យ ដែលជាគ្រូឧទ្ទេសនាមមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញចាប់ពីថ្ងៃទី០៥ដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ក្រោមអធិបតីភាពលោក អ៊ុក សមវិទ្យា នាយក ប.ស.ស និងមន្ត្រីក្រោមឱវាទដែលជាសិក្ខាកាមចូលរួមជាច្រើននាក់ផងដែរ។ រយៈពេលកន្លងមក ប.ស.ស បានអញ្ជើញគ្រូឧទ្ទេសនាមមកពីក្រសួង/ស្ថាប័ន អង្គភាពពាក់ពន្ធ័នានាជាច្រើនលើក ដើម្បីផ្តល់នូវពុទ្ធិស្មើរគ្រប់ផ្នែករបស់ផ្ទៃក្នុងអង្គភាព និងការងារពាក់ព័ន្ធក្រៅអង្គភាព ដើម្បីឱ្យថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីមានសមត្ថភាពពេញ លេញក្នុងការដឹកនាំអង្គភាពឆ្ពោះទៅរកភាពរុងរឿងទៅថ្ងៃអាណាគត់។



ទិដ្ឋភាពចូលរួមរបស់សិក្ខាកាមក្នុងវគ្គសិក្សា

ដើម្បីពង្រឹងបន្ថែមនូវសមត្ថភាពដឹកនាំការងាររបស់ថ្នាក់ដឹកនាំក្នុងអង្គភាព ប.ស.ស ចាប់ពីអនុប្រធានការិយាល័យឡើងទៅឱ្យមានភាពរឹងមាំ និងមានគុណភាពទ្វេរឡើងនោះ អង្គភាពបានបង្កើត ឱ្យមានវគ្គបណ្តុះបណ្តាលរយៈពេល ២សប្តាហ៍ ដោយ



ការចូលរួមក្នុងវគ្គសិក្សារបស់មន្ត្រី ប.ស.ស

និងបម្រើវិស័យសន្តិសុខសង្គមជូន ដល់សមាជិករបស់ខ្លួនឱ្យបានល្អថែមទៀត។ ក្នុងឱកាសដ៏សំខាន់នោះ លោក អ៊ុក សមវិទ្យា នាយក ប.ស.ស បានណែនាំដល់មន្ត្រី ក្រោមឱវាទឱ្យមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការសិក្សា ដោយក្រេបយកចំណេះដឹងដ៏ល្អនេះដឹកនាំអង្គភាពឱ្យបានប្រសើរថ្លៃថ្លា ដែលហេតុផលនេះទាមទារឱ្យថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីបង្កើន សមត្ថភាពបន្ថែមមិនមែនតែការងារជំនាញចំពោះមុខប៉ុណ្ណោះទេ ថែមទាំងមានការយល់ដឹងឱ្យបានទូលាយអំពីបញ្ហាសង្គមផ្សេងៗក្នុង និងក្រៅអង្គភាព ដែលបានជួបប្រទះបញ្ហាប្រឈមជាច្រើន ឈាន ដល់ការធ្វើការដោះស្រាយឱ្យបានទាន់ពេលវេលា ឱ្យស្របទៅនឹងការសន្និដ្ឋានរួម របស់ទស្សនអ្នកសង្គមវិទូថា "មានសង្គម មានបញ្ហា និងមានការដោះស្រាយឱ្យទាន់ពេល"៕

# ប្រជុំពិគ្រោះយោបល់សាធារណៈ ស្តីពីការកំណត់តាវកាលិកផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិត

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បាននឹងកំពុងដាក់ ឱ្យដំណើរការនូវរបបថែទាំសុខភាព ដែលជាជំហានទី២ ដោយធ្វើការសិក្សាស្រាវជ្រាវបង្កើតនូវច្បាប់បទដ្ឋានគតិយុត្ត និងគោលការណ៍ច្បាប់ផ្សេងៗ ដើម្បីឱ្យផ្នែកនេះធានាបាននៅពេលសមាជិកខ្លួនទទួលរងនូវបញ្ហាសុខភាព និងជួយសម្រាលនូវរាល់ទុក្ខលំបាក ដោយជំងឺផ្សេងៗ ដែលកើតមានឡើងក្រៅពីគ្រោះថ្នាក់ការងារ។ ស្របជាមួយគ្នានេះ កាលពីព្រឹកថ្ងៃសុក្រទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានបើកកិច្ចប្រជុំពិគ្រោះយោបល់សាធារណៈ ស្តីពីការកំណត់តាវកាលិក



លោក អ៊ុក សមវិទ្យា នាយក ប.ស.ស អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ



ការចូលរួមកិច្ចប្រជុំពិគ្រោះយោបល់របស់តំណាងនិយោជក សហជីព និងអង្គភាពពាក់ព័ន្ធ

ផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិត ក្រោមអធិបតីភាពលោក អ៊ុក សមវិទ្យា នាយកបេឡាជាតិរបបសន្តិសុខសង្គម និងមន្ត្រីក្រោមឱវាទ ប្រធាននាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (cambodia), តំណាងសមាគមរោងចក្រ កាត់ដេរកម្ពុជា (GMAC), តំណាងអង្គការវិជ្ជាជីវៈ និងតំណាងនិយោជក រួមទាំងសហជីពមូលដ្ឋានរបស់រោងចក្រទាំង១១ដែលស្ថិតនៅក្នុងគម្រោងផ្នែកថែទាំសុខភាពផងដែរ។ ក្នុងឱកាសនោះ លោក អ៊ុក សមវិទ្យា នាយកបេឡាជាតិរបបសន្តិសុខសង្គម បានលើកឡើងថាការកំណត់តាវកាលិកផ្នែកថែទាំសុខភាព គឺជាផ្នែកមួយជួយសម្រាលបន្ទុករបស់កម្មករនិយោជិត ពេលជួបបញ្ហាដោយសារសុខភាព និងជាយន្តការដែលត្រូវមានសនិទ្ធភាព និងសង្គតិភាពនឹងគ្នា ដោយមិនអាចទទួលត្រឹមតែការគាំពារចំពោះជំងឺ ឬគ្រោះថ្នាក់ដែលបណ្តាលមកពីការងារប៉ុណ្ណោះទេប៉ុន្តែត្រូវមានការគាំពារជំងឺ ឬគ្រោះថ្នាក់ទូទៅ ដែលមិនពាក់ព័ន្ធនឹងគ្រោះថ្នាក់ការងារផងដែរ។ លោកនាយកបានលើកឡើងទៀតថា គោលបំណងក្នុងថ្ងៃនេះ គឺជាការប្រជុំមានលក្ខណៈបើកចំហរជាសាធារណៈ ដើម្បីមានមូលដ្ឋានរាយការណ៍ជូន ក្រសួងអាណាព្យាបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឈានទៅអនុវត្តផ្នែកនេះបានពេញលេញ និងគ្រប់ជ្រុងជ្រោយ ដែលទាមទារឱ្យមានការចូលរួមមតិពិគ្រោះយោបល់ ក្នុងការស្វែងរកចំណុចរួមណាមួយ ដើម្បីធ្វើការដោះស្រាយ និងអនុវត្តតាម ដោយបម្រើសេវាសាធារណៈជូន ដល់សមាជិកឱ្យមានតម្លាភាព ប្រសិទ្ធភាព និងមានភាពឆាប់រហ័ស៕



# វគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណកម្មករនិយោជិត

ដើម្បីឱ្យការអនុវត្តផ្នែកថែទាំសុខភាពនេះទទួលជោគជ័យ អាស្រ័យទៅលើការធ្វើការផ្នែកណាមួយឱ្យបានល្អជាងនេះ ជាពិសេសទៅលើការកំណត់អត្តសញ្ញាណ របស់ដៃគូរពាក់ព័ន្ធឱ្យបានច្បាស់លាស់ក្នុងការបម្រើសេវា ជូនពួកគាត់ឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដែលទាមទារឱ្យមន្ត្រី,បុគ្គលិក គ្រប់ផ្នែកនៃ ប.ស.ស ពង្រឹងសមត្ថភាពបន្ថែម។ ទន្ទឹមគ្នានេះ ប.ស.ស បានបើកវគ្គបណ្តុះបណ្តាលរយៈពេល (បីថ្ងៃ) ស្តីពីការកំណត់អត្តសញ្ញាណកម្មករនិយោជិត ចាប់ពីថ្ងៃទី ១៧-១៨-១៩ ខែធ្នូ ឆ្នាំ២០១៤ ក្រោមអធិបតីភាព លោក អ៊ុក សមវិទ្យា នាយក ប.ស.ស លោកនាយករង អស់លោក លោកស្រី ប្រធាន អនុប្រធានការិយាល័យ និងមានសិក្ខាកាមចូលរួម ដែលជាមន្ត្រី បុគ្គលិកសាខា ប.ស.ស ខេត្តទាំង ២៣ខេត្ត/ក្រុង ចំនួន ៦១នាក់។ ក្នុងឱកាសដ៏ថ្លៃថ្លានោះ លោក អ៊ុក សមវិទ្យា នាយក ប.ស.ស មានមតិស្វាគមន៍ និងណែនាំដល់សិក្ខាកាម និងមន្ត្រីក្រោមឱវាទឱ្យមានការយកចិត្តទុកដាក់ក្រេបជញ្ជក់ចំណេះដឹង ស្តីពីការកំណត់អត្តសញ្ញាណកម្មករនិយោជិត តាមប្រព័ន្ធបច្ចេកទេសព័ត៌មានវិទ្យាថ្មី (New Information Technology System) ដើម្បីធ្វើការកំណត់ឱ្យមានភាពជាក់លាក់ណាមួយ បង្កឱ្យមានភាពងាយស្រួលក្នុងការបម្រើសេវាសាធារណៈ



ការអញ្ជើញជាអធិបតីរបស់ លោក អ៊ុក សមវិទ្យា នាយកប.ស.ស ក្នុងការបើកវគ្គបណ្តុះបណ្តាល

ជូនដល់សមាជិក របស់អង្គភាព ដែលជាអ្នកទទួលសេវាឱ្យបានល្អត្រឹមត្រូវ និងទាន់ពេលវេលា ស្របទៅនឹងអង្គភាព បាននឹងកំពុងដាក់ឱ្យដំណើរការ ផ្នែកធានារ៉ាប់រងសុខភាព ដែលជាជំហានទី២ បន្ទាប់ពីផ្នែកធានារ៉ាប់រងហានិភ័យការងារ (គ្រោះថ្នាក់ការងារ) ដែលជាជំហានទី១។ ក្នុងឱកាសនោះដែរ លោកនាយកបានអនុញ្ញាតឱ្យធ្វើការរិះគន់ ដើម្បីស្ថាបនាលើប្រព័ន្ធ Face Book ដើម្បីធ្វើការកែលំអជាសាធារណៈ នូវលក្ខណៈអសកម្មរបស់មន្ត្រី,បុគ្គលិក ប.ស.ស ឬអង្គភាពផ្ទាល់ ឬការធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ណាមួយរបស់អតិថិជនដែលជាដៃគូររបស់អង្គភាពផងដែរ៕


ការចូលរួមរបស់មន្ត្រី,បុគ្គលិក សាខា ប.ស.ស ខេត្តក្នុងវគ្គបណ្តុះបណ្តាល

# វគ្គបណ្តុះបណ្តាល ស្តីពីវិជ្ជាសង្គ្រោះបឋម

ការសង្គ្រោះបឋមជាផ្នែកមួយសំខាន់ដែរ ដែលទាមទារឱ្យបុគ្គលិក, មន្ត្រីត្រូវមាន ចំណេះដឹងផ្នែកនេះ ដើម្បីធ្វើការសង្គ្រោះ ជីវិត ឬបង្កភាពងាយស្រួលក្នុងការសង្គ្រោះ និងព្យាបាលនៅលើកទី២។ ជាក់ស្តែងកាល ពីថ្ងៃទី០៤-០៥ ខែធ្នូ ឆ្នាំ២០១៤ បេឡាជាតិ របបសន្តិសុខសង្គម បានបើកវគ្គបណ្តុះ បណ្តាលរយៈពេលខ្លី ស្តីពីវិជ្ជាសង្គ្រោះបឋម បង្រៀនដោយគ្រូឧទ្ទេសនាម មកពីកាកបាទ ក្រហមកម្ពុជា ដោយមានសិក្ខាកាមចូលរួម



ទិដ្ឋភាពចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីវិធីសង្គ្រោះបឋមរបស់មន្ត្រី ប.ស.ស និងមន្ត្រីមកពីអង្គភាពពាក់ព័ន្ធ



ការអនុវត្តជាក់ស្តែងបន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល

មកពីមជ្ឈមណ្ឌលជាតិផ្តល់ឈាម និងមន្ត្រី ប.ស.ស ផ្ទាល់ជាច្រើននាក់ផងដែរ។ វគ្គបណ្តុះបណ្តាលមានគោលបំណងឱ្យសិក្ខាកាម យល់ដឹងអំពីវិធីសង្គ្រោះបឋម ដែលក្នុងនោះមានការសង្គ្រោះជីវិត, ការបង្ការរបួសកុំឱ្យធ្ងន់ធ្ងរថែមទៀត, ការធ្វើឱ្យជនរងគ្រោះមានអារម្មណ៍កក់ក្តៅ ដើម្បីរក្សាភាពរឹងមាំ, ការធ្វើឱ្យជនរងគ្រោះអាចទទួលបានការថែទាំវេជ្ជសាស្ត្របានឆាប់រហ័ស និងដើម្បីជួយសម្រួលដល់គ្រូពេទ្យងាយព្យាបាល។ម្យ៉ាងទៀត, ការសង្គ្រោះបឋមនេះ មានតួនាទីកាត់បន្ថយការឈឺចាប់, កាត់បន្ថយភាពធ្ងន់ធ្ងរ, ការពារគ្រោះថ្នាក់ជាលើកទី២, ប្រកាសអាសន្នរកអ្នកជំនួយ, និងមានការលើកដាក់បញ្ជូនជនរងគ្រោះឱ្យបានត្រឹមត្រូវទៅតាមបច្ចេកទេស៕



# ដំណើរទស្សនកិច្ចសិក្សារបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ទៅប្រទេសអាឡឺម៉ង់

ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម មានតួនាទី និងភារកិច្ច បង្កើតឱ្យមានកិច្ចប្រជុំអនុម័តច្បាប់បទដ្ឋានគតិយុត្ត នានាទាក់ទងទៅនឹងកិច្ចដំណើរការ នៃប្រព័ន្ធសន្តិសុខសង្គមរបស់អង្គភាព ដោយបង្កើតជាគោលការណ៍រួមមួយ ក្នុងការជួយសម្រាល នូវរាល់ទុក្ខលំបាកនានារបស់កម្មករនិយោជិត ដែលជាបច្ច័យមួយ សម្រាប់ជួយគ្នាទៅវិញទៅមក។ មិនតែប៉ុណ្ណោះក្រុមប្រឹក្សាភិបាល នៃប.ស.ស បានធ្វើការសិក្សាស្រាវជ្រាវគោលការណ៍ច្បាប់ផ្សេងៗ នៅក្រៅប្រទេស ទាក់ទងនឹងប្រព័ន្ធសន្តិសុខសង្គម ដោយបាន អញ្ជើញទៅទស្សនកិច្ចសិក្សានៅប្រទេសអាឡឺម៉ង់កាលពីថ្ងៃទី២០ ដល់២៤ ខែតុលា ឆ្នាំ២០១៤ នៅក្រសួង ស្ថាប័ន អង្គភាព ចំនួន៥ រួមមាន៖ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ចការងារ សមាគម មន្ទីរពេទ្យ មន្ទីរពេទ្យវីវិន (Vivantes) និងសមាគម AOK ស្តីពី ប្រព័ន្ធសន្តិសុខសង្គម ដែលស្ថិតនៅក្នុងប្រទេសនេះ។ កន្លងមក អង្គភាពបានអនុវត្តបានជោគជ័យជាបណ្តើរៗនូវផ្នែកមួយ គឺផ្នែក ធានារ៉ាប់រងហានិភ័យការងារ និងផ្នែកពីរទៀត ដែលទាមទារឱ្យ អង្គភាពធ្វើការសិក្សាស្រាវជ្រាវជាបន្ត បន្ទាប់ និងដាក់ឱ្យដំណើរ ការនៅពេលឆាប់ៗខាងមុខ ដើម្បីបម្រើសេវាសាធារណៈជូនដល់ កម្មករនិយោជិតឱ្យបានទាន់ពេលវេលា។ ហេតុផលនេះហើយ ទើបធ្វើឱ្យអង្គភាព និងផ្នែកពាក់ព័ន្ធបានខិតខំប្រឹងប្រែង និងយក ចិត្តទុកដាក់ខ្ពស់ ក្នុងការសិក្សាស្រាវជ្រាវគ្រប់ក្រសួង ស្ថាប័ន/ អង្គភាពពាក់ព័ន្ធក្នុង និងក្រៅប្រទេសដែលទាក់ទងនឹងប្រព័ន្ធសន្តិ សុខសង្គម។ គោលបំណងសំខាន់ នៃដំណើរទស្សនកិច្ចសិក្សា របស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស គឺដើម្បីធ្វើការសិក្សាស្រាវ ជ្រាវប្រព័ន្ធសន្តិសុខសង្គម នៅប្រទេសអាឡឺម៉ង់ ដោយធ្វើការ



លោក អ៊ុក សមវិទ្យា នាយកប.ស.ស ចូលរួមក្នុងកិច្ចប្រជុំនៅប្រទេសអាឡឺម៉ង់



ប្រៀបធៀបជាមួយនឹងប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ដែលអង្គ ភាពបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ត្រូវបានឱ្យដាក់អនុវត្តប្រព័ន្ធនេះ ក្នុងនោះមាន (ផ្នែកធានារ៉ាប់រងហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែក សោធន សម្រាប់កម្មករនិយោជិត) និងដកស្រង់បទពិសោធន៍ ដោយស្វែងរកគោលការណ៍សំខាន់ៗរួមណាមួយជាប្រយោជន៍ សម្រាប់ដោះស្រាយភាពអសកម្ម និងការប្រឈមនានាក្នុងកិច្ច ដំណើរការនៃការអនុវត្តផ្នែកទាំងនេះឱ្យបានល្អប្រសើរ និងមាន ប្រសិទ្ធភាពខ្ពស់៕



ទិដ្ឋភាពប្រជុំពិគ្រោះយោបល់របស់ថ្នាក់ដឹកនាំ ប.ស.ស

# សន្និសីទអន្តរជាតិ ស្តីពីការគាំពារសង្គមឆ្នាំ២០១៤ នៅប្រទេសម៉ាឡេស៊ី

ការពង្រីក និងពង្រឹងវិសាលភាពនៃការគាំពារសង្គម គឺជាផ្នែកមួយដ៏លំបាកបំផុតទាមទារឱ្យអង្គភាព និងផ្នែកពាក់ព័ន្ធសហការស្អិតរមួតនិយាយជារួម។ និយាយដោយឡែកវិស័យសន្តិសុខសង្គមក៏ដូចច្នេះដែរ ទាមទារឱ្យមានការពង្រឹងគ្រប់ផ្នែកពាក់ព័ន្ធក្នុងវិស័យនេះ ដែលជាយន្តការមួយត្រូវបានពង្រឹងបន្ថែមទៀតដើម្បីគ្របដណ្តប់ និងធ្វើការបញ្ចូលគ្នាឱ្យបានទូលំទូលាយក្នុងការអភិវឌ្ឍន៍ឱ្យមានភាពរីកចំរើន។ ក្នុងបរិបទនេះ បេឡាជាតិរបបសន្តិសុខសង្គម បានចាត់មន្ត្រីរបស់ខ្លួនឱ្យចូលរួមសន្និសីទលើកទី២ ស្តីពីការគាំពារសង្គម ឆ្នាំ២០១៤ នាមជ្ឈមណ្ឌលស្រាវជ្រាវសន្តិសុខសង្គម នៃមហាវិទ្យាល័យរដ្ឋបាល និងសេដ្ឋកិច្ច និងមកពីបណ្ឌាសាកលវិទ្យាល័យម៉ាឡេស៊ី អង្គភាពសន្តិសុខសង្គមអាស៊ាន វាគ្មិនអន្តរជាតិដទៃទៀត។ គោលបំណងសំខាន់នៃសន្និសីទ គឺផ្តោតទៅលើការពិភាក្សាពីបញ្ហាថ្មីៗលើផ្នែកសន្តិសុខសង្គម, ការផ្តល់នូវវេទិការសម្រាប់ផ្លាស់ប្តូរគំនិត និងទស្សនពីនិន្នាការដែលកំពុងរីកចំរើនលើផ្នែកសន្តិសុខសង្គម និងជំរុញនូវសំលេងមួយមានមូលដ្ឋានគ្រឹះក្នុងការកសាងភាតរភាពក្នុងចំណោមមនុស្សមានការងារដូចគ្នាចំពោះការគាំពារសង្គម៕



ការអញ្ជើញមានចំណាប់អារម្មណ៍ របស់បណ្តាប្រទេសចូលរួមក្នុងអង្គសន្និសីទ



ទិដ្ឋភាពចូលរួមរបស់សិក្ខាកាម ចូលរួមក្នុងអង្គសន្និសីទ នៅប្រទេសម៉ាឡេស៊ី



# សិក្ខាសាលា ស្តីពីរបបធានារ៉ាប់រងសង្គម និងវេទិកាពិភាក្សា ស្តីពីការគាំពារសង្គម នៅប្រទេសបង់ក្លាដេស

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានពង្រឹងការងាររបស់ខ្លួនតាមរយៈបញ្ជូនមន្ត្រីជំនាញពាក់ព័ន្ធដទៃទៀត ដើម្បីដកស្រង់បទពិសោធន៍ ការងារមួយចំនួនទាក់ទងទៅនឹងកិច្ចដំណើរការ នៃវិស័យសន្តិសុខសង្គម ដែលផ្នែកមួយចំនួនក្នុងវិស័យនេះបានដំណើរការជាបណ្តើរៗ និងផ្នែកដទៃទៀតបាននឹងកំពុងដាក់ឱ្យដំណើរការនាពេលឆាប់ៗខាងមុខនេះ។ ស្របគ្នានេះកាលពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៤ រយៈពេលកន្លងមក ប.ស.ស បានបញ្ជូនមន្ត្រីជំនាញរបស់ខ្លួន, អ្នកជំនាញការជនជាតិអាល្លឺម៉ង់ប្រចាំនៅប.ស.ស និងអ្នកជំនាញការមកពីអង្គការជាតិ អន្តរជាតិពាក់ព័ន្ធ ទៅចូលរួមសិក្ខាសាលាស្តីពីរបបធានារ៉ាប់រង សុខភាព និងវេទិកាពិភាក្សាស្តីពីការគាំពារសង្គម រៀបចំឡើង ដោយផ្នែក Global Social Responsibility នាទីក្រុងDhaka ប្រទេស Bangladesh ដែលមានសមាសភាពចូលរួម មកពីគ្រប់បណ្តាស្ថាប័នពាក់ព័ន្ធប្រមាណជាង ៦៥០នាក់។ ក្នុងឱកាសនោះដែរ



បទបង្ហាញរបស់ លោក ហេង សុផាន់ណារិទ្ធ ក្នុងអង្គសិក្ខាសាលា



ទិដ្ឋភាពអ្នកចូលរួមសិក្ខាសាលា ក្នុងអង្គពិធី

លោក ហេង សុផាន់ណារិទ្ធ អនុប្រធានការិយាល័យធានារ៉ាប់រងសុខភាព នៃប.ស.ស បានធ្វើជាវាគ្មិន ក្នុងការពិភាក្សាវេទិកាសាធារណៈស្តីពីការគាំពារសង្គម ដែលសំដៅទៅលើការបង្កើនការអភិវឌ្ឍន៍ធនធានមនុស្ស, ការរៀបចំ និងប្រើប្រាស់ឧបករណ៍ជាច្រើនប្រភេទដើម្បីការពារបុគ្គលការពារគ្រួសារ និងសហគមន៍ពីប្រភេទផ្សេងៗនៃផលវិបាកផ្នែកហិរញ្ញវត្ថុសេដ្ឋកិច្ច និងសង្គម ដែលកើតឡើងពីហានិភ័យ ឬវិបត្តិផ្សេងៗក្នុងការជួយពួកគាត់ឱ្យចាកផុតពីភាពក្រីក្រ។ អង្គសិក្ខាសាលានេះ គឺផ្តោតសំខាន់ទៅលើផ្នែកហានិភ័យការងារ និងសុខមាលភាពរបស់កម្មករនិយោជិត។



ការថតរូបអនុស្សាវរីយ៍របស់សិក្ខាកាមចូលរួមក្នុងអង្គសិក្ខាសាលា

គោលបំណងនៃការចូលរួមនេះ គឺដើម្បីធ្វើការប្រៀបធៀបការអនុវត្តជាក់ស្តែង ចូលរួមចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក ដកស្រង់ នូវគោលការណ៍រួមណាមួយបង្កើតចេញជាបែបបទ និងនីតិវិធីផ្សេងៗ ជាប្រយោជន៍ក្នុងការដោះស្រាយនូវ រាល់ការប្រឈមនានាក្នុងការប្រតិបត្តិផ្នែកនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

# លទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមការងារ ស.ផ.ក លើការពិនិត្យកែសម្រួល ខ្លឹមសារវីដេអូអប់រំ (ស្ព័ត) ស្តីពីវិជ្ជាសង្គ្រោះបឋម

ដើម្បីឱ្យការងារអនុវត្តបានគ្រប់ជ្រុងជ្រោយមានភាពរលូន និងប្រសិទ្ធភាពខ្ពស់យើងត្រូវធ្វើការតាមដាន និងកំណត់ឱ្យបាននូវទិន្នន័យជាក់លាក់ណាមួយក្នុងការតម្រង់ទិស ដែលអាចបង្កឱ្យមានភាពងាយស្រួលក្នុងការប្រតិបត្តិការងារនោះ។ ស្របជាមួយគ្នានេះ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ នៅសាលប្រជុំក្រុមប្រឹក្សាភិបាល នៃប.ស.ស ក្រុមសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត បានបើកកិច្ចប្រជុំពិភាក្សាការងាររបស់ខ្លួនក្រោមអធិបតីភាព លោក អ៊ុក សមវិទ្យា នាយក ប.ស.ស និងជាប្រធានក្រុមការងារ, ដែលមានសមាជិកចូលរួមតំណាងមកពីក្រសួង /ស្ថាប័ន អង្គភាពពាក់ព័ន្ធជាច្រើនរូប។



ទិដ្ឋភាពចូលរួមរបស់ក្រុមការងារ ក្នុងកិច្ចពិភាក្សា



កិច្ចពិភាក្សាលើការពិនិត្យកែសម្រួលខ្លឹមសារវិដេអប់រំ ស្តីពីវិជ្ជាសង្គ្រោះបឋម

គោលបំណងនៃកិច្ចប្រជុំ គឺសម្រាប់ធ្វើការពិនិត្យកែសម្រួលលើខ្លឹមសារវីដេអូអប់រំខ្លី (ស្ព័ត) ស្តីពីវិជ្ជាសង្គ្រោះបឋម ដើម្បីផ្សព្វផ្សាយអប់រំណែនាំ ដល់កម្មករនិយោជិត ក៏ដូចជាអ្នកបើកបរដឹកកម្មករនិយោជិតឱ្យយល់ដឹង និងចេះពីវិជ្ជាសង្គ្រោះបឋម មុនពេលបញ្ជូនជនរងគ្រោះទៅសង្គ្រោះនៅមន្ទីរពេទ្យ៕

# លទ្ធផលនៃកិច្ចប្រជុំពិភាក្សាលើការរៀបចំខ្សែវីដេអូអប់រំខ្លី សម្រាប់ធ្វើការផ្សព្វផ្សាយ

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានបង្កើតឡើងដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលាយ និងបានជ្រួតជ្រាប ដល់អ្នកបើកបរដឹកកម្មករនិយោជិតតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន និងក្រុមហ៊ុនដទៃទៀតឱ្យបានយល់ច្បាស់ និងប្រតិបត្តិតាមច្បាប់ចរាចរណ៍ ដើម្បីកាត់បន្ថយគ្រោះថ្នាក់របស់បងប្អូនកម្មករនិយោជិត ឱ្យស្ថិតនៅកម្រិតទាបបំផុតដែលអាចទៅបាន។ ស្របគ្នានេះដែរ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ ក្រុមការងារ បានបើកកិច្ចប្រជុំពិភាក្សាការងារមួយចំនួន ដែលទាក់ទងទៅនឹងការបង្កើត និងកែសម្រួលជាវីដេអូអប់រំខ្លីមួយសម្រាប់ធ្វើការផ្សព្វផ្សាយបន្ថែមដល់អ្នកបើកបរកម្មករនិយោជិត ឱ្យបានជ្រួតជ្រាប



លោក អ៊ុក សមវិទ្យា នាយក ប.ស.ស និងអ្នកជំនាញពាក់ព័ន្ធ ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា

និងអនុវត្តឱ្យបានខ្ជាប់ខ្ជួន តាមអ្វីដែលក្រុមការងារបានណែនាំក្នុងខ្សែវីដេអូនេះ។

រយៈពេលកន្លងមកនេះ ក្រុមការងារបានធ្វើការផ្សព្វផ្សាយបានទូលាយ ប៉ុន្តែការអនុវត្តរបស់ភាគីពាក់ព័ន្ធនៅមានកម្រិត ដូចនេះហើយទើបក្រុមការងារបានបង្កើតឱ្យមានជាខ្សែវីដេអូថ្មីមួយទៀតដើម្បីអប់រំណែនាំបន្ថែមឱ្យមានប្រសិទ្ធភាពល្អជាងមុន។



ទិដ្ឋភាពប្រជុំពិភាក្សារបស់ក្រុមការងារ

# ក្រុមការងារ ស.ទ.ប.ក ចុះពិនិត្យករណីសន្លប់ នៅរោងចក្រ SUNBEST



ក្រុមការងារ របស់គណៈកម្មការ ស.ទ.ប.ក បានចុះសម្របសម្រួលនៅរោងចក្រដែលកើតហេតុ

ដើម្បីឱ្យមានភាពចំណេញខាងផ្នែកផលិតទាំងពេលវេលាប្រាក់កាសទាំងទ្រព្យសម្បត្តិ និយោជកដែលជាម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តតាមអ្វីដែលផ្នែកពាក់ព័ន្ធបានណែនាំ មិនដូច្នេះទេនិយោជកអាចនឹងជួបប្រទះនូវហានិភ័យទាំងនេះជាក់ជាមិនខាន។ ស្របគ្នានេះកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ មានករណីឆ្លងចរន្តអគ្គីសនី កើតឡើងនៅរោងចក្រ SUNBEST ស្ថិតនៅផ្លូវជាតិលេខ៤ ស្រុកអង្គស្នួល ខេត្តកណ្ដាល ករណីនេះកើតឡើងក្នុងបរិវេណធ្វើការផ្ទាល់របស់កម្មករនិយោជិតបណ្ដាលឱ្យកម្មករនិយោជិតសន្លប់ចំនួនប្រមាណ៦៩នាក់ ករណីសន្លប់មានការកើនឡើងច្រើន គឺផ្ដើមចេញពីកម្មករនិយោជិតម្នាក់ ដែលនៅជិតកន្លែងកើតហេតុមានអារម្មណ៍ភ័យ និងមានអាការៈវិលមុខ ទន់ដៃទន់ជើង ហើយសន្លប់តៗគ្នាច្រើននាក់តែម្ដង។ ការសន្លប់របស់កម្មករនិយោជិត មានការពាក់ព័ន្ធជាច្រើនកត្តាបណ្ដាលមកពីនិយោជកផ្ទាល់ មានការធ្វេសប្រហែសក្នុងការពិនិត្យតាមដានសកម្មភាពការងាររបស់សមាជិកខ្លួន និងមិនបានបំពេញនូវលក្ខខណ្ឌការងារដែលផ្នែកពាក់ព័ន្ធបានណែនាំ។ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ បានចុះទៅសម្របសម្រួល និងបានធ្វើការណែនាំឱ្យនិយោជកប្រតិបត្តិតាមច្បាប់ និងតាមការណែនាំដូចជា៖

- ឱ្យមានការយកចិត្តទុកដាក់ខ្ពស់អំពីសុខភាពកម្មករនិយោជិត (ផ្ដល់របបចំណីអាហារនៅពេលមានការថែមម៉ោង,អប់រំណែនាំបន្តដល់កម្មករនិយោជិតអំពីលក្ខខណ្ឌអនាម័យ,....)



ការសួរនាំដើម្បីរកមូលហេតុរបស់ក្រុមការងារ

- ឱ្យនិយោជកគោរពលក្ខខណ្ឌការងារដែល ប.ស.ស និងផ្នែកពាក់ព័ន្ធបានធ្វើការអប់រំផ្សព្វផ្សាយ (មានការធ្វើការថែមម៉ោងដោយស្ម័គ្រចិត្ត សម្រាកឱ្យគ្រប់គ្រាន់,អនុញ្ញាតឱ្យកម្មករចូលធ្វើការតាមការកំណត់របស់គ្រូពេទ្យ ក៏ដូចជាតាមការណែនាំរបស់ផ្នែកជំនាញ...)។

ករណីសំខាន់ក្នុងការសន្លប់នេះ ក៏ទាក់ទងទៅនឹងការធ្វើការថែមម៉ោងរយៈពេលពីរម៉ោង ប្រមាណជិត០២ខែផងដែរ៕

# កម្មករនិយោជិតសន្លប់បណ្តាលមកពីផ្សែងហុយចូលអគាររោងចក្រផលិតកម្ម នៅរោងចក្រ JTH TEXTILE (CAMBODIA)



ទិដ្ឋភាពនៃកិច្ចប្រជុំពិភាក្សារបស់គណៈកម្មការ ស.ទ.ប.ក

ករណីសន្លប់របស់កម្មករនិយោជិត បានកើតឡើងជាញឹកញាប់តាមបណ្តារោងចក្រមួយចំនួនដោយសារការមិនគោរពលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ និងលក្ខខណ្ឌដទៃទៀតដែលនិយោជកមិនទាន់បានអនុវត្តឱ្យបានត្រឹមត្រូវ និងលក្ខខណ្ឌដាច់ដោយឡែកមួយនៃចិត្តសាស្ត្រសង្គម របស់កម្មករនិយោជិតផ្ទាល់ផងដែរ។ ស្របជាមួយគ្នានេះ គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ស.ទ.ប.ក) បានចុះទៅអង្កេតករណីសន្លប់នៅរោងចក្រ JTH TEXTILE (CAMBODIA) ស្ថិតនៅសង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ករណីនេះកើតឡើងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ដែលមានកម្មការិនីសន្លប់ចំនួន៤៥នាក់។ មូលហេតុគឺបណ្តាលមកពីមានផ្សែងហុយពីរោងចក្រដែលនៅក្បែរនោះ ចូលទៅក្នុងរោងចក្រដែលកើតហេតុផ្ទាល់តែម្តង។ ការសន្លប់គឺផ្តើមចេញពីមានកម្មការិនីពីរ ឬបីនាក់មានអាការៈភិតភ័យ, ថប់ដង្ហើម, ផ្អើលស្លន់ស្លោ, ទន់ដៃទន់ជើង រហូតបណ្តាលឱ្យកម្មការិនីផ្សេងៗទៀតមានអាការៈដូចគ្នា បន្ទាប់មកក៏បណ្តាលឱ្យសន្លប់តៗគ្នាជាច្រើននាក់។ ឯកឧត្តមវេជ្ជបណ្ឌិត ប៉ុក វណ្ណថាត ប្រធានគណៈកម្មការ ស.ទ.ប.ក ក្រុមការងារសហការជាមួយផ្នែកពាក់ព័ន្ធ បានចុះសម្របសម្រួលជួយសង្គ្រោះ និងបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យបានទាន់ពេលវេលា។ ការដឹកជញ្ជូន និងសេវាថែទាំព្យាបាលផ្សេងៗ ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ លោកប្រធានគណៈកម្មការបានធ្វើការណែនាំ និងដាក់វិធានការដល់និយោជក ដើម្បីធ្វើការកែលំអដូចខាងក្រោម៖

-រៀបចំលាងសំអាតផ្លិតទឹកនៃប្រព័ន្ធខ្យល់ត្រជាក់ ដើម្បីបញ្ចៀសក្លិនផ្សែងដែលហុយចូល និងបើកប្រព័ន្ធខ្យល់ត្រជាក់ឱ្យបានប្រហែល៣០នាទី មុននឹងកម្មករនិយោជិតចូលធ្វើការ។

-អនុញ្ញាតឱ្យកម្មករនិយោជិត ចូលធ្វើការតាមថ្ងៃកំណត់របស់គណៈកម្មការជំនាញបានណែនាំ និងក្រោមការត្រួតពិនិត្យរបស់គ្រូពេទ្យដើម្បីឃ្លាំមើលពីស្ថានភាពសុខភាព មុននឹងអនុញ្ញាតឱ្យកម្មករចូលធ្វើការជាធម្មតាវិញ។ ការធ្វើនេះគឺដើម្បីទប់ស្កាត់ និងបង្ការកុំឱ្យករណីនេះកើតឡើងជាថ្មីម្តងទៀត៕



ម៉ាស៊ីនដែលបង្កឱ្យមានផ្សែងហុយចូលរោងចក្រ



ការសម្របសម្រួលបញ្ជូនជនរងគ្រោះទៅកាន់មន្ទីរពេទ្យ

# ករណីកម្មការិនីសន្លប់ នៅរោងចក្រ Great Union (Cambodis) Garmant Co.Ltd ដោយសារធំក្លិនប្រេងម៉ាស៊ីន និងក្លិនផ្សែងដុតសំរាមនៅក្បែរអាគាររោងចក្រផលិតកម្ម





ទិដ្ឋភាពប្រជុំពិភាក្សារបស់គណៈកម្មការជាមួយតំណាងរោងចក្រ និងសហជីពដើម្បីសាកសួរពីមូលហេតុដែលបង្កឲ្យកម្មករកម្មការិនីសន្លប់

កម្មករនិយោជិត ២៣នាក់ សន្លប់ដោយសារធំក្លិនផ្សែងប្រេងម៉ាស៊ីនដែលចូលទឹកត្រូវបានចម្រាញ់ ដើម្បីប្រើឡើងវិញនៅក្បែរច្រាំងទន្លេរបស់សាឡង់បូមប្រេង និងក្លិនផ្សែងដុតសំរាមទើបធ្វើឱ្យកម្មករនិយោជិត នៅរោងចក្រ Great Union (Cambodia) Garment Co.,Ltd មានការភិតភ័យ ថប់ដង្ហើម ទន់ដៃទន់ជើងសន្លប់តៗគ្នា កាលពីវេលាម៉ោងប្រមាណជា១០ និង២០នាទីព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ថិតនៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ក្នុងករណីកម្មករសន្លប់ ខាងលើនេះ គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ បានចុះត្រួតពិនិត្យពីស្ថានភាព និងប្រជុំជាមួយតំណាងរោងចក្រ Great Union (Cambodia) Garment Co.,Ltd បានសន្និដ្ឋានថាករណី កម្មករនិយោជិតសន្លប់ទាំង ២៣នាក់ បណ្តាលមកពីធំក្លិនផ្សែងប្រេងម៉ាស៊ីនដែលចូលទឹកត្រូវបានចម្រាញ់ ដើម្បីប្រើឡើងវិញនៅក្បែរច្រាំងទន្លេរបស់សាឡង់បូមប្រេង បានធ្វើឱ្យហុយផ្សែងចូលក្នុងរោងចក្រមានក្លិនដូចអង់ទ្រីន និងដូចក្លិនថ្នាំស្អុយ ទើបបង្កឱ្យកម្មករនិយោជិតមានអាការៈ ធីងធោង ថប់ដង្ហើម ទន់ដៃ ទន់ជើង ត្រូវបានមកសង្គ្រោះបឋមនៅគិលានដ្ឋាន ទើបរដ្ឋបាលរោងចក្របញ្ជូនបន្តទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកជ័យជំនះ។ រហូតមកដល់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៥កម្មករនិយោជិតដែលសន្លប់ បានត្រឡប់មកធ្វើការជាធម្មតា។

ករណីដែលបង្កឲ្យកម្មករនិយោជិតសន្លប់ គណៈកម្មការបានដាក់វិធានការជូនសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើការកែលំអនូវចំនុចខ្វះខាតមួយចំនួនដូចជា៖ ស្នើឱ្យកែលំអប្រព័ន្ធខ្យល់ចេញចូល នៅអាគារជាន់ក្រោមផ្ទាល់ដី ឱ្យបានត្រឹមត្រូវតាមប្រកាសលេខ១២៥ សកបយ។ ប្រធានរដ្ឋបាល និងគ្រូពេទ្យគិលានដ្ឋានរបស់រោងចក្រ ត្រូវណែនាំអប់រំដល់កម្មករនិយោជិតឱ្យយល់ដឹងរបបចំណីអាហារទាំងបីក្រុម និងបរិភោគឱ្យបានទៀងទាត់៕



កន្លែងការងាររបស់កម្មករនិយោជិតមុនពេលកើតហេតុ

# ប.ស.ស បានផ្សព្វផ្សាយគោលនយោបាយថ្មីៗ ដល់នាយក ម្ចាស់សហគ្រាស គ្រឹះស្ថាន នៅខេត្តប៉ៃលិន



លោក ម៉េង ហុង នាយករង ប.ស.ស ឡើងធ្វើបទបង្ហាញស្ដីពីការធ្វើបច្ចុប្បន្នភាព

ដើម្បីឱ្យការងារមានភាពរលូន និងទាន់ពេលវេលាក្នុងការបម្រើសេវាសាធារណៈជូនដល់កម្មករនិយោជិត បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានរិះរកគ្រប់មធ្យោបាយ និងគ្រប់នីតិវិធី ដោយធ្វើបច្ចុប្បន្នភាពការងារគ្រប់ផ្នែក តាមរយៈការផ្សព្វផ្សាយឱ្យបានទូលាយ និងបានជ្រួតជ្រាបដល់និយោជក និងផ្នែកពាក់ព័ន្ធដទៃទៀត ដើម្បីបម្រើសេវាឱ្យមានភាពល្អប្រសើរ និងទាន់ពេលវេលា។ជាមួយគ្នានេះកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ នៅខេត្តប៉ៃលិន ប.ស.ស បានរៀបចំពិធីប្រជុំផ្សព្វផ្សាយ ស្ដីពីការអនុវត្តគោលនយោបាយថ្មីៗ និងការពង្រឹងសេវានៃការផ្ដល់តាវកាលិកហានិភ័យការងារ ក្រោមការដឹកនាំប្រជុំដោយ លោក ម៉េង ហុង នាយករង នៃ ប.ស.ស និងមានការចូលរួមពីតំណាងនិយោជក ផ្នែកពាក់ព័ន្ធជាច្រើនរូបទៀត។ លោក ម៉េង ហុង នាយករង នៃ ប.ស.ស បានធ្វើបទបង្ហាញ និងពន្យល់ណែនាំអំពីបែបបទ និងនីតិវិធីនៃការផ្ដល់តាវកាលិក (អត្ថប្រយោជន៍) ហានិភ័យការងារ សេវាមន្ទីរពេទ្យ និងសេវារបស់ធនាគារដែលកំណត់ដោយ ប.ស.ស (អេស៊ីលីដា) និងតម្រូវឱ្យនិយោជកយកចិត្តទុកដាក់ខ្ពស់ ក្នុងការស្វែងយល់ឱ្យបានស៊ីជម្រៅជាមួយផ្នែកពាក់ព័ន្ធ ជាពិសេសអង្គភាព ប.ស.ស ផ្ទាល់ជាបច្ច័យដ៏សំខាន់មួយក្នុងការដោះស្រាយឱ្យបានទាន់ពេលវេលានូវអ្វីដែលជាភាពអសកម្មរាំងស្ទះ និងអ្វីជាការប្រឈមទាក់ទងទៅនឹងការប្រតិបត្តិការងារ ដើម្បីពន្លឿនសេវាសាធារណៈជូនដល់កម្មករនិយោជិតឱ្យបានលឿន និងទាន់ពេលវេលា ។

ការងាររលូន និងមានភាពល្អប្រសើរទៅបាន ល្គឹកណាតែផ្នែកពាក់ព័ន្ធសហការឱ្យបានស្អិតរមួត ដោយធ្វើការរួមគ្នាជាធ្លុងមួយជាមួយអង្គភាព ប.ស.ស ផងដែរ៕



ការចូលរួមរបស់សិក្ខាកាមក្នុងអង្គពិធី

# អាហារដែលមានអត្ថប្រយោជន៍ដល់សុខភាព



**ចេកជួយបង្ការរោគគាំងបេះដូង៖** ចេកគឺជាផ្លែឈើដែលសំបូរទៅដោយសារជាតិចិញ្ចឹម វាមានរសជាតិផ្អែម និងក្រអូប។ ចេកមិនត្រឹមតែជាផ្លែឈើស្រស់សម្រាប់ទទួលទានប៉ុណ្ណោះទេ ប៉ុន្តែចេកផ្តល់គុណប្រយោជន៍ផងដែរចំពោះសុខភាព។ ការស្រាវជ្រាវមួយបានថ្លែងថា ប្រសិនបើយើងទទួលទានចេកជារៀងរាល់ថ្ងៃ យើងនឹងមានការប្រថុយប្រថានតិចជាង២២% ចំពោះរោគគាំងបេះដូងជាងមនុស្សដែលមិនដែលបានទទួលទានចេកសោះ។ មិនតែប៉ុណ្ណោះចេកមានកាល់ស្យូមខ្ពស់ អាចបង្កើនភាពទៀងទាត់នៃចង្វាក់បេះដូង, ដំណើរជំរុញនៃសាច់ដុំឱ្យមានសកម្មភាពឡើង និងជួយឱ្យសម្ពាធឈាមថេរ។

**ពិសាល្ហុងទុំជួយដល់បញ្ហាទល់លាមក៖** ល្ហុងទុំគឺជាផ្លែឈើដែលត្រូវបានគេចាត់ទុកថាមានផលល្អសម្រាប់អ្នកដែលមានបញ្ហាទល់លាមក ព្រោះវាជួយឱ្យបន្ទោរបង់បានស្រួល។ ការទទួលទានល្ហុងទុំ ១ពែងនៅពេលល្ងាចអាចជួយឱ្យអ្នកបន្ទោបង់បានស្រួលនៅពេលព្រឹក។ ម្យ៉ាងទៀតវាអាចជួយបំបាត់បញ្ហាទល់លាមក និងការពារមិនឱ្យកើតជំងឺឫដូងបាតទៀតផងដែរ។ ក្រៅពីនេះល្ហុងទុំសម្បូរទៅដោយជីវជាតិសំខាន់ជាច្រើន ដែលមានផលល្អដល់សុខភាពជាពិសេស វីតាមីន C ប្រូតេអ៊ីន ជាតិទឹក កាល់ស្យូម និងផូស្វ័រ៕





**ទទួលទានស្វាយទុំមានប្រយោជន៍ចំពោះកែវភ្នែក៖** ក្រុមគ្រូពេទ្យជំនាញផ្នែកភ្នែកនៅសហរដ្ឋអាមេរិចបានធ្វើការពិសោធន៍រកឃើញថា ផ្លែស្វាយជាប្រភេទរុក្ខជាតិម្យ៉ាងមានគុណសម្បត្តិជួយថែរក្សាភ្នែក ជាពិសេសភ្នែកវ័យចាស់ជរាភាគច្រើនចុះខ្សោយ។ ផ្លែស្វាយជួយបំប៉នភ្នែកបានល្អជាងមើមការ៉ុតព្រោះនៅក្នុងផ្លែស្វាយសម្បូរទៅដោយវិតាមីន C វីតាមី E និងបេតាការ៉ូទីន។ អ្នកស្រាវជ្រាវផ្នែកសុខភាពបានណែនាំទៀតថា ប្រសិនបើបានទទួលទានផ្លែស្វាយជួយកាត់បន្ថយភាពប្រឈម ក្នុងការបាត់បង់កែវភ្នែកពិសេសអ្នកមានវ័យជរាច្រើន ដែលតែងតែមានអាការៈសមធឈាមឡើងខ្ពស់។

**ទទួលទានម្នាស់ជួយបង្ការជំងឺរលាកតម្រងនោម៖** ម្នាស់ជាប្រភេទផ្លែឈើដែលមានគុណប្រយោជន៍ច្រើនយ៉ាង ការទទួលទានម្នាស់ជាប្រចាំអាចជួយបង្ការជំងឺរលាកតម្រងនោម សម្ពាធឈមាខ្ពស់ (ជួយបន្ថយសម្ពាធឈាម) រលាកបំពង់ខ្យល់ ព្រមទាំងជួយរំលាយអាហារប្រភេទសាច់បានល្អ និងជួយប្រឆាំងរោគផ្តាសាយ ឬភាពមិនប្រសើរផ្សេងទៀតក្នុងខ្លួនដូចជាការក្អក ក្រដាសឈឺបំពង់ក តឹងច្រមុះ និងហាសម្បោរជាដើម ដោយមានអាកាសធាតុត្រជាក់ ទាំងនេះគឺជាឱកាសដែលធ្វើឱ្យជំងឺផ្តាសាយវាយលុកប្រព័ន្ធភាពស៊ាំរបស់យើងដែលកំពុងធ្លាក់ចុះខ្សោយ៕



អត្ថបទដកស្រង់ចេញពី www.healthcambodia.org/posts/7873

# ទស្សនគួរពិចារណា


ប្រសិនបើ ធន់ខ្សោយ សូមឲ្យរឹងមាំ
ប្រសិនបើ ភ័យខ្លាច សូមឲ្យក្លាហាន
ប្រសិនបើ ធាល់ច្រក សូមឲ្យកែខៃ
ប្រសិនបើមិនមានអ្នកណាស្រឡាញ់
ក៏សូមឲ្យស្រឡាញ់ខ្លួនឯង


មនុស្សល្អមិនចាំបាច់មានមុខមាត់ល្អ
មនុស្សល្អមិនចាំបាច់តែងខ្លួនឲ្យល្អ
មនុស្សល្អមិនចាំបាច់មានឋានៈល្អ
តែមនុស្សល្អ គឺមនុស្សមានដួងចិត្តល្អ
ចាំងធ្វើអំពើល្អដល់មនុស្សសត្វទូទៅ


គូសត្រូវដ៏ខ្លាំងពូកែ យើងមិនអាចកែប្រែបានទេ
អ្វីដែលកែប្រែបាន
គឺធ្វើឲ្យខ្លួនឯងខ្លាំងពូកែជាងសត្រូវ


" គ្មានអំណាចណាដែលនៅ
ឋិតថេរជាអមតៈនោះទេ"
No empire lasts forever
Vladimir Lenin


បើអ្នកស្រលាញ់ខ្ញុំសូមកុំសរសើរខ្ញុំទាំងដឹងថាខ្ញុំខុស
ព្រោះវាធ្វើអោយខ្ញុំខុសម្តងហើយម្តងទៀតដោយមិនដឹងខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**

លេខ :...១០/១៥.........ប.ស.ស

# សេចក្តីជូនដំណឹង
# ស្តីពីនីតិវិធីនៃការបង់ភាគទាន

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សូមជូនដំណឹងចំពោះគ្រប់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានជ្រាបថា ដើម្បីសម្រួលដល់ដំណើរការនៃការបង់ភាគទាន ប.ស.ស សូមធ្វើការណែនាំដូចខាងក្រោម ៖

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីបេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់ ។ ការបង់ភាគទានអាចត្រូវបានអនុវត្តតាមរបៀបដូចខាងក្រោម ៖

១- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់ផ្ទាល់នៅធនាគារដូចមុនដដែល ឬ

២- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់តាមរយៈសេវាកម្មអ៊ិនធើណែតប៊ែងឃីង (Internet Banking) ឬ សេវាកម្មយូនីធី (Unity) ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ តទៅ ។ រាល់ការចំណាយសេវាកម្មនេះជាបន្ទុកផ្ទាល់របស់និយោជក ។

៣- ចំពោះបង្កាន់ដៃបង់ភាគទាន របាយការណ៍ចំនួនកម្មករនិយោជិត របាយការណ៍ប្រាក់ឈ្នួល ឬ ឯកសារចាំបាច់នានា និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកមកដាក់ដោយផ្ទាល់នៅការិយាល័យ ប.ស.ស ឬ ផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬ ផ្ញើតាមសារអេឡិចត្រូនិច contribution@nssf.gov.kh ។

***បញ្ជាក់ ៖***

ចំពោះលោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទានរួចហើយ ផ្ញើរបាយការណ៍កម្មករនិយោជិតតាមរយៈសារអេឡិចត្រូនិច ត្រូវមានឯកសារដូចជា ៖

- របាយការណ៍កម្មករនិយោជិត (ទម្រង់អេឡិចត្រូនិច E-Form)
- លិខិតប្រកាសបង់ភាគទានហានិភ័យការងារ
- លិខិតបញ្ជាក់ពីនិយោជក (Form B)
- តារាងបើកប្រាក់បៀវត្សរកម្មករ និយោជិត (ទម្រង់អេឡិចត្រូនិច Payroll)

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ទាំងអស់ នឹងចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះជាក់ជាពុំខាន ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០១៤



អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៩៩ ៨៤ ១៧ ០២៣-៩៩ ៨៤ ១៨ , ០២៣ ៩៩ ៨៤ ១៩
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

# របៀបបង់ភាគទានសម្រាប់បេឡាជាតិរបបសន្តិសុខសង្គម (បសស)

## User Manual of NSSF Contribution Payment via ACLEDA Internet Bank

ACLEDA Internet Bank

### សម្រាប់ *RIB*

• របៀបបង់ភាគទាន / How to make contribution payment

▸ សូមចូលទៅកាន់វេបសាយធនាគារ អេស៊ីលីដា តាមរយៈ "www.acledabank.com.kh" ជ្រើសរើស "Retail Customer" រួចចុចប៊ូតុង "Login" ។
Please go to ACLEDA Website "www.acledabank.com.kh", select "Retail Customer", then click on "Login".




1

លោកអ្នកអាចជ្រើសរើសភាសាខ្មែរ - អង់គ្លេស ឬ ចិន តាមតម្រូវការ / You can select languages as Khmer, English or Chinese of your choice.

សូមបញ្ចូលឈ្មោះសម្គាល់អ្នកប្រើប្រាស់
Please enter your User ID




4 សូមចុច "Login"
Please click on "Login"

សូមបញ្ចូលលេខសម្ងាត់ផ្ទាល់ខ្លួន
Please enter your own Password

សូមបញ្ចូលលេខសម្ងាត់ដែលទទួលបានពី Soft Token ឬ Hard Token / Please enter One Time Password generated by Soft Token or Hard Token




សូមចុច "Login"
Please click on "Login"

2

សូមចុច "Pay Bills"
Please click on "Pay Bills"

សូមជ្រើសរើសយក "400-NSSF"
Please select "400-NSSF"




សូមជ្រើសរើស "NSSF" រួចចុចប៊ូតុង "Show" ដើម្បីបញ្ចូលលេខអត្តសញ្ញាណសហគ្រាស
Please select "NSSF", then click on the button "Show" to enter consumer ID

3

សូមបញ្ចូល "លេខអត្តសញ្ញាណសហគ្រាស" នៅលើវិក្កយបត្រក្នុងប្រអប់ "Consumer ID" រួចចុចប៊ូតុង "Search"/ Please enter Consumer ID, then click on the button "Search"

សូមជ្រើសរើសលេខគណនី រួចបញ្ចូលចំនួនទឹកប្រាក់ដែលត្រូវទូទាត់
Please select account number and enter amount you wish to make bill payment




12 សូមចុចប៊ូតុង "Submit" / Please click on the button "Submit"

4

13 បន្ទាប់មកសូមលោកអ្នកផ្ទៀងផ្ទាត់មើលព័ត៌មានលម្អិតខាងក្រោម រួចបញ្ចូលលេខសម្ងាត់ (OTP) ដែលទទួលបានពី Soft Token ឬ Hard Token រួចចុចប៊ូតុង "Confirm" / Please verify the payment details and enter One Time Password generated by Soft Token or Hard Token, then click on the button "Confirm".




5

14 ការបង់វិក្កយបត្រទទួលបានជោគជ័យ លោកអ្នកអាចចុចប៊ូតុង "Print" ប្រសិនបើចង់បោះពុម្ពទុកជាឯកសារ, ឬចុច "Register Biller" ដើម្បីរក្សាទុកឈ្មោះក្រុមហ៊ុនសម្រាប់បង់វិក្កយបត្រនៅពេលបន្ទាប់ / Your company bill has been processed successfully, then click on the button "Print" if you want to keep it as reference , or click on "Register Biller" to save company bill for next payment.




6

## របៀបបង់ភាគទានសម្រាប់ បេឡាជាតិរបបសន្តិសុខសង្គម (បសស) តាមរយៈសេវាអេស៊ីលីដាយូនីធី

## How to pay NSSF contribution via ACLEDA Unity

**1** ជាដំបូងសូមលោកអ្នកចុចលើ "Log On" ដើម្បីចូលទៅប្រើប្រាស់សេវាអេស៊ីលីដាយូនីធី ។
First, please log in ACLEDA Unity.




**2** សូមបញ្ចូលលេខសម្ងាត់ រួចចុច "Enter" ។
Enter your PIN and then click on "Enter".




**3** សូមចុចលើ "Bill Payment" ។
Please select "Bill Payment".




**4** សូមចុច "Make Bill Payment" ។
Please select "Make Bill Payment".




**5** សូមចុច "NSSF" ។
Please select "NSSF".




**6** សូមជ្រើសរើសគណនីណាមួយដែលត្រូវកាត់ប្រាក់ចេញ ។
Please select the account to be debited.




**7** សូមចុច "Create New Consumer Number" ដើម្បីបង្កើតលេខវិក្កយបត្រថ្មី ។
Please click on "Create New Consumer Number" to create new number of bill payment.




**8** សូមបញ្ចូលលេខអត្តសញ្ញាណសហគ្រាសដែលមាននៅលើវិក្កយបត្រ ទៅក្នុងប្រអប់ Consumer Number រួចចុច "NEXT" ។
Please enter the organization or company ID Number into the box Consumer Number, then press "NEXT".




**9** សូមបញ្ចូលចំនួនទឹកប្រាក់ត្រូវបង់ជាប្រាក់រៀល រួចចុច "NEXT" ។
Please enter the amount of your contribution, then press "NEXT".




**10** សូមផ្ទៀងផ្ទាត់ព័ត៌មានបង់ប្រាក់លម្អិត រួចចុច "YES" ។
Please verifiy the payment detials then press "YES".




**11** ខាងក្រោមជារបាយការណ៍បញ្ជាក់ពីការបង់ភាគទានសម្រាប់បេឡាជាតិរបបសន្តិសុខសង្គមបានជោគជ័យ ។
Your payment has been processed successfully.



# សម្រាប់ CIB

• របៀបបង់ភាគទាន / How to make contribution payment

១-១ Maker

▸ សូមចូលទៅកាន់វេបសាយធនាគារ អេស៊ីលីដា តាមរយៈ "www.acledabank.com.kh" ជ្រើសរើស "Corporate Customer" រួចចុចប៊ូតុង "Login" ។
Please go to ACLEDA Website "www.acledabank.com.kh", select "Corporate Customer", then click on "Login".



1

លោកអ្នកអាចជ្រើសរើសភាសាខ្មែរ - អង់គ្លេស ឬ ចិន តាមតម្រូវការ / You can select languages as Khmer, English or Chinese of your choice.

សូមបញ្ចូលលេខសម្ងាត់ដែលទទួលបានពី Soft Token ឬ Hard Token / Please enter One Time Password generated by Soft Token or Hard Token



សូមបញ្ចូលឈ្មោះសម្គាល់អ្នកប្រើប្រាស់
Please enter your User ID

សូមចុច "Login"
Please click on "Login"

សូមបញ្ចូលលេខសម្ងាត់ផ្ទាល់ខ្លួន
Please enter your own Password



សូមចុច "Login"
Please click on "Login"

2

សូមចុច "Bill Payment"
Please click on "Bill Payment"



8 សូមចុច "Pay Bill"
Please click on "Pay Bill"

សូមចុច "Pay Bill"
Please click on "Pay Bill"

3

សូមជ្រើសរើសលេខ biller (400) ដែលត្រូវធ្វើការបង់ប្រាក់
Please select biller number (400) to be paid



សូមជ្រើសរើសយក "NSSF"
Please select "NSSF"

12 សូមបញ្ចូលលេខអត្តសញ្ញាណសហគ្រាសដែលមាននៅលើវិក្កយបត្រ / Please enter consumer ID

សូមចុចប៊ូតុង "Search" / Please click on the button "Search"

14 សូមចុចលើ "NSSF"
Please select on "NSSF"

4

សូមបញ្ចូលចំនួនទឹកប្រាក់ដែលត្រូវទូទាត់
Please enter "Payment Amount"



សូមជ្រើសរើសលេខគណនីដែលត្រូវកាត់ប្រាក់ចេញ
Please select "Debit Account"

សូមចុចប៊ូតុង "Submit"
Please click on the button "Submit"

5

18 បន្ទាប់មកសូមលោកអ្នកផ្ទៀងផ្ទាត់មើលព័ត៌មានលម្អិតខាងក្រោម រួចបញ្ចូលលេខសម្ងាត់ (OTP) ដែលទទួលបានពី Soft Token ឬ Hard Token រួចចុចប៊ូតុង "Confirm" / Please verify the payment details and enter One Time Password generated by Soft Token or Hard Token, then click on the button "Confirm".



6

១-២ Checker

សូមចុច "Bill Payment"
Please click on "Bill Payment"



សូមចុច "Pay Bill"
Please click on "Pay Bill"

សូមចុច "View Pending Entries"
Please click on "View Pending Entries"

សូមចុច "Authorize"
Please click on "Authorize"

5 សូមបញ្ចូលលេខសម្ងាត់ដែលទទួលបានពី Soft Token ឬ Hard Token
Please enter One Time Password generated by Soft Token or Hard Token

7

6 ការបង់វិក្កយបត្រទទួលបានជោគជ័យ លោកអ្នកអាចចុចប៊ូតុង "Print" ប្រសិនបើចង់បោះពុម្ពទុកជាឯកសារ / Your company bill has been processed successfully, then click on the button "Print" if you want to keep it as reference.



8



# ទូរស័ព្ទ ១២៨៦

# ក្រុមប្រចាំការ Hotline 24 ម៉ោង

ចាប់តាំងពីការដាក់ឱ្យដំណើរការផ្នែកធានារ៉ាប់រងហានិភ័យការងារ (គ្រោះថ្នាក់ការងារ) រហូតមកដល់បច្ចុប្បន្នមានរយៈពេលជិត ៦ឆ្នាំមកហើយ ដោយទទួលបានជោគជ័យគួរជាទីមោទនៈ។ ទន្ទឹមនឹងភាពជោគជ័យនេះ បេឡាជាតិរបបសន្តិសុខសង្គម បាននឹងកំពុងរៀបចំដាក់ឱ្យដំណើរការផ្នែកធានារ៉ាប់រងសុខភាព ដែលជាជំហានទី ០២ របស់ខ្លួន ដែលគម្រោងនឹងឱ្យដំណើរការនៅឆាប់ៗខាងមុខ និងដើម្បីរួមចំណែកក្នុងការជំរុញឱ្យផ្នែកធានារ៉ាប់រងសុខភាព ទទួលបានជោគជ័យ ដូចផ្នែកធានារ៉ាប់រងហានិភ័យការងារ ក្រុមការងារ HOTLINE ដែលជាផ្នែកមួយដ៏សំខាន់ នៃបេឡាជាតិរបបសន្តិសុខសង្គម បានត្រៀមខ្លួនរួចជាស្រេច ទាំងសមត្ថភាព និងជំនាញក្នុងការបម្រើសេវា ផ្នែកធានារ៉ាប់សុខភាព ដែលនឹងដាក់ឱ្យដំណើរការនាពេលដ៏ឆាប់ខាងមុខនេះ ឱ្យមានប្រសិទ្ធភាពនិងប្រកបដោយលទ្ធផលល្អប្រសើរ។ ភាពជោគជ័យនេះ គឺបានមកដោយសារការខិតខំប្រឹងប្រែង ពីគ្រប់បណ្តាផ្នែកទាំងអស់នៃបេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងនោះក៏មានក្រុមការងារ HOTLINE នៃការិយាល័យគោលនយោបាយផងដែរ។

ជាក់ស្តែងក្នុងត្រីមាសទី១ ឆ្នាំ២០១៨ ក្រុមការងារ HOTLINE បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម និងទទួលបានលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ និងទទួលព័ត៌មានពីសមាជិក បេឡាជាតិរបបសន្តិសុខសង្គម បានជាច្រើនលើក, ធ្វើការសម្របសម្រួល សម្រាប់សេវាសង្គ្រោះបន្ទាន់បានជាច្រើនដង, ទទួលបានព័ត៌មានករណីសន្លប់បានជាច្រើនករណី, និងធ្វើការសម្របសម្រួលនូវបញ្ហាសមាជិកទទួលរងគ្រោះថ្នាក់រហូតដល់សន្លប់បានមួយចំនួនដល់ស្លាប់ បានមួយចំនួនទៀត។

ទន្ទឹមនឹងទទួលបានលទ្ធផលជាផ្លែផ្កាក្តី ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែរដែលតម្រូវឱ្យក្រុមការងារ HOTLINE នៅតែខិតខំប្រឹងប្រែងដោះស្រាយរាល់ការប្រឈមនោះ ឱ្យមានភាពរលូន និងរហ័សទាន់ពេលវេលា ដើម្បីបម្រើសេវាសាធារណៈ ជូនដល់សមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គម ឱ្យបានល្អបន្ថែមទៀត៕



សកម្មភាពទំនាក់ទំនងការងារ របស់អតិថិជនជាមួយក្រុមការងារ HotLine

# សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត

**ទីស្នាក់ការកណ្តាល ប.ស.ស រាជធានីភ្នំពេញ**

អាសយដ្ឋាន: អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៨៨២ ៨៣៤, ០២៣ ៩៩៨ ៩១៧
០២៣ ៩៩៨ ៩១៨, ០២៣ ៩៩៨ ៩១៩
ទូរសារ: ០២៣ ៨៨២ ៦២៣
គេហទំព័រ: www.nssf.gov.kh

**សាខា ប.ស.ស ខេត្តសៀមរាប**

អាសយដ្ឋាន: ផ្ទះលេខP១០ ភូមិត្រពាំងសេះ ឃុំគោកចក ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទដៃ: ០១២ ៥៣៤ ៣៩៥, ០៧៧ ៦៦៣ ២១៧
ទូរស័ព្ទ: ០៦៣ ៩៦៥ ៩៣៤
គេហទំព័រ: www.nssf.gov.kh
E-mail: pang_sokchea@yahoo.com

**សាខា ប.ស.ស ខេត្តកណ្តាល**

អាសយដ្ឋាន: ផ្ទះលេខ២០១ ផ្លូវលេខ២០២ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល
ភូមិក្នុង ផ្លូវផ្សារព្រែកតាមាក់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
ទូរស័ព្ទ: ០២៤ ៦៤០ ១៦៧៦, ០៧៧ ៩៦៣ ០៧៨
E-mail: kandal_@nssf.gov.kh

**សាខា ប.ស.ស ខេត្តបន្ទាយមានជ័យ**

អាសយដ្ឋាន: ភូមិគីឡូម៉ែតលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ: ០៥៤ ៧១១ ៩៩១, ០៧៧ ៦៦៣ ២១៨
E-mail: nssf_bmc@nssf.gov.kh

**សាខា ប.ស.ស ខេត្តកំពង់ស្ពឺ**

អាសយដ្ឋាន: ផ្ទះលេខ៣៦A ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ: ០២៤ ៦៨៨ ០០៩៧, ០៧៧ ៩៧០ ៩០៧
E-mail: nssf_ksp@nssf.gov.kh
movratha@nssf.gov.kh

**សាខា ប.ស.ស ខេត្តកំពង់ចាម**

អាសយដ្ឋាន: ផ្លូវជាតិលេខ៧ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ទូរស័ព្ទ: ០៤២ ៦៥២ ១៩៩៩, ០៧៧ ៩៩០ ០៤៨
E-mail: nssf_kpc@nssf.gov.kh
say.sothon@nssf.gov.kh

**សាខា ប.ស.ស ខេត្តព្រះសីហនុ**

អាសយដ្ឋាន: សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរស័ព្ទ: ០៣៤ ៩៣៤ ៦០៦, ០៧៧ ៦៦៣ ២១៥
E-mail: nssf_shv@nssf.gov.kh
tong_samnieng@nssf.gov.kh

**សាខា ប.ស.ស ខេត្តកំពង់ធំ**

អាសយដ្ឋាន: ភូមិទី៧, សង្កាត់កំពង់ធំ, ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
ទូរស័ព្ទ: ០៦២ ២១០ ៩៦៣, ០៩២ ៧៤៧ ០៩៩
E-mail: kp_thom@nssf.gov.kh
ly_sokha2007@yahoo.com

**សាខា ប.ស.ស ខេត្តស្វាយរៀង**

អាសយដ្ឋាន: ផ្លូវជាតិលេខ១ ភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង
ទូរស័ព្ទ: ០៤៤ ៧១៥ ៨៣១, ០៧៧ ៦៦៣ ២១៤
E-mail: pek.samol@nssf.gov.kh

**សាខា ប.ស.ស ខេត្តព្រៃវែង**

អាសយដ្ឋាន: ផ្ទះលេខ១០៧ ភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
ទូរស័ព្ទ: ០៩២ ៧០៨ ៨០៣, ០១២ ៥៤៨ ៨០៥
E-mail: preyveng@nssf.gov.kh
reythearith@yahoo.com

**សាខា ប.ស.ស ខេត្តកំពង់ឆ្នាំង**

អាសយដ្ឋាន: ផ្ទះលេខC495 ភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុមទី១៨ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ: ០២៦ ៧៧៥ ៥៦៦, ០៧៧ ៦៦៣ ២១៦
E-mail: nssf_kcn@nssf.gov.kh

**សាខា ប.ស.ស ខេត្តក្រចេះ**

អាសយដ្ឋាន: ភូមិកោះកណ្តាលទី១ សង្កាត់កោះកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ
ទូរស័ព្ទ: ០៩២ ៨៧៣ ០៥១, ០៧៧ ៩៧០ ៩០៤
E-mail: kratie@nssf.gov.kh
soksay.he@nssf.gov.kh

### សាខា ប.ស.ស ខេត្តកំពត
អាសយដ្ឋាន: ភូមិ១ឧសភា ឃុំកំពង់កណ្ដាល ស្រុកកំពង់បាយ ក្រុងកំពត ខេត្តកំពត
ទូរស័ព្ទ: ០៣៣ ៩៣២ ១៣៣, ០១២ ៦២៣ ៣៣២
E-mail: kompot@nssf.gov.kh
phakchetra@gmial.com

### សាខា ប.ស.ស ខេត្តពោធិ៍សាត់
អាសយដ្ឋាន: ផ្ទះលេខ០០៧ ភូមិរ៉ា សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
ទូរស័ព្ទ: ០៥២ ៩៥១ ១២៣, ០៩២ ៧០៧ ៣៨៥
E-mail: nssf_ps@nssf.gov.kh

### សាខា ប.ស.ស ខេត្តបាត់ដំបង
អាសយដ្ឋាន: ផ្ទះលេខP៩ បូរីពាណិជ្ជកម្មបាត់ដំបង
ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ទូរស័ព្ទ: ០៥៣ ៩៥៣ ៣៣៦, ០៩៧ ៩៩៧ ២៤២៩
E-mail: battambang@nssf.gov.kh

### សាខា ប.ស.ស ខេត្តកោះកុង
អាសយដ្ឋាន: ផ្ទះលេខ២៦ ក្រុម២ ភូមិ៣ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
ទូរស័ព្ទ: ០៣៥ ៩៣៦ ៩៣៦, ០៩៧ ៩៧៣ ៩០០៦
E-mail: kongkea.nssf.kk@gmail.com

### សាខា ប.ស.ស ខេត្តប៉ៃលិន
អាសយដ្ឋាន: ភូមិវត្ត សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
ទូរស័ព្ទ: ០៥៥ ៩៥៦ ៦៦៧, ០៨៦ ៨៩៣ ៧៧៧
E-mail: somit.ream@nssf.gov.kh

### សាខា ប.ស.ស ខេត្តតាកែវ
អាសយដ្ឋាន: ផ្លូវលេខ១០ ភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
ទូរស័ព្ទ: ០៣២ ២១០ ៦៦៦, ០១២ ៦៣៦ ៨៣៩
E-mail: soun.vannak@nssf.gov.kh

### សាខា ប.ស.ស ខណ្ឌដង្កោ
អាសយដ្ឋាន: ផ្ទះលេខ១១២A ផ្លូវវេងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ (ទល់មុខផែរស្វូតស្វូរង្គួន)
ទូរស័ព្ទ: ០១២ ៦៩៥ ៥៥០, ០២៣ ៩៩៥ ៨៨៩
E-mail: lpl@nssf.gov.kh

### សាខា ប.ស.ស ខេត្តរតនគិរី
អាសយដ្ឋាន: ភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី
ទូរស័ព្ទ: ០៩៧ ៩៦៦ ៧៦៦៦, ០១១ ៩៥១ ៧៧៧
០៧៥ ៩៧៤ ១៨៤
E-mail: sam_ath@nssf.gov.kh

### សាខា ប.ស.ស ខេត្តមណ្ឌលគិរី
អាសយដ្ឋាន: ភូមិចំបក់ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
ទូរស័ព្ទ: ០១២ ២០៥ ៧៥៦, ០៨៨ ៨២០ ៥៧៥៦
E-mail: kosol_vicheth@yahoo.com

### សាខា ប.ស.ស ខេត្តឧត្តរមានជ័យ
អាសយដ្ឋាន: ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ
ទូរស័ព្ទ: ០៩៧ ៥២៣ ៤៦៦៦ ០៨៥ ៣១១ ៣០០
E-mail: simao2013@gmial.com

### សាខា ប.ស.ស ខេត្តស្ទឹងត្រែង
អាសយដ្ឋាន: ភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
ទូរស័ព្ទ: ០១២ ៤០៥ ៤៥១
E-mail: nganrathana@gmial.com

### សាខា ប.ស.ស ខេត្តព្រះវិហារ
អាសយដ្ឋាន: ភូមិកណ្ដាល ឃុំកំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
ទូរស័ព្ទ: ០៩៧ ៣៦៦ ៦០៦០, ០១២ ២៥៩ ២៥៨
E-mail: nssf_pvh@nssf.gov.kh
savuth22@gmail.com

### សាខា ប.ស.ស ខណ្ឌឫស្សីកែវ
អាសយដ្ឋាន: ផ្ទះលេខ៥០ EoE1 ផ្លូវលេខ៣ ក្រុមទី៤ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៦៦៣ ៣០៣០, ០៩២ ៤៨៦ ២៥៦
E-mail: vannaknssf@gmial.com

# បញ្ជីឈ្មោះមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានីខេត្ត |
|---|---|---|---|---|---|
| ០១ | មន្ទីរពេទ្យកាលម៉ែត | ១១៩ | ០២៣ ៤២៦ ៩៤៨<br>០២៣ ៧២៤ ៨៩១ | ០៩៧ ៦៨៧ ២៤២៦<br>០៧៧ ៩៧៨ ៤៧៤ | ភ្នំពេញ |
| ០២ | មន្ទីរពេទ្យព្រះកុសុមៈ | ១១៩ | ០១២ ៦៥៧ ៦៥៣<br>០១៦ ៩០៩ ៧៧៤ | ០៩៧ ៦៨៧ ២៤២៩<br>០៩២ ៨២០ ២៥៩<br>០១២ ៦៦៩ ៩៤៦ | |
| ០៣ | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១១៩<br>០៧៨ ៩៩៧ ៩៧៨ | ០២៣ ២១៧ ៧៦៤<br>០១២ ៨៥៨ ១៨៤ | ០៩៧ ៦៨៧ ២៤២៧<br>០៩២ ៥៩១ ៣៧៧<br>០១២ ៣០៥ ៣៧១ | |
| ០៤ | មន្ទីរពេទ្យព្រះអង្គឌួង | ០១៦ ៥០៥ ៤៥៣ | ០១១ ៧៥៥ ១១៩<br>០៧៧ ៥៥០ ០១៧ | | |
| ០៥ | មណ្ឌលសុខភាពទួលគោល | ១១៩<br>០១២ ៥១៩ ៩១៦ | ០១១ ៨៣៣ ៣៣៩<br>០២៣ ៣៥១ ១៩៨ | | |
| ០៦ | មន្ទីរពេទ្យបង្អែកសម្តេចឪ | ១១៩<br>០៧៨ ៣៩៨ ៦៦៧ | ០១២ ៥៣២ ៨០៣<br>០១២ ៨៦៤ ៥០៩ | | |
| ០៧ | មណ្ឌលសុខភាពទឹកថ្លា | ១១៩<br>០៧៧ ៧៩៧ ៩៦៧ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | | |
| ០៨ | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង | ១១៩<br>០១២ ៨៥៣ ០១៣ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | | |
| ០៩ | មណ្ឌលសុខភាពគោករកា | | ០១៧ ៧៧៥ ៤៧២ | | |
| ១០ | មណ្ឌលសុខភាពស្ទឹងមានជ័យ | | ០១២ ៩៧១ ៤៧៦ | ០៧៧ ៦៣៦ ៣៦០ | |
| ១១ | មន្ទីរពហុព្យាបាល និងសម្ភព សុខ លាភ មេត្រី | ០១១ ៣៩៨ ៨៨៨ | ០២៣ ៦៦៦ ៦២៣៧<br>០១២ ៦០៣ ១៣១ | | |
| ១២ | មន្ទីរសម្រាកព្យាបាលមូលមិត្ត | ០៩៧ ៧៦៣ ៩០០៣ | ០១២ ៤៤៩ ៦០៨ | | |
| ១៣ | មន្ទីរពេទ្យជ័យជំនះ | ០១៥ ៥១៩ ១១៩ | ០១២ ៩១២ ៥២៣<br>០៧៧ ៩៣៣ ៤៥៩ | ០៩៧ ៦៨៧ ២៤២៨ | កណ្តាល |
| ១៤ | មណ្ឌលសុខភាពបែកចាន | ០១២ ៥៧១ ៦៦៦<br>០១២ ១៧៥ ៨២៨៥<br>០៩៧ ៤៩៩ ៨៩៣៦ | ០១២ ៨៩៤ ២៦០ | ០៩៧ ២៩៩ ៦៦៦៩<br>០៩៦ ៣៦៩ ៥៩១២ | |
| ១៥ | មន្ទីរពេទ្យបង្អែកអង្គស្នួល | ០១២ ៥៨១ ៦៣៩ | ០១២ ៨៩៤ ២៦០<br>០៦៩ ៧០៥ ៧៥៧ | | |
| ១៦ | មន្ទីរពេទ្យបង្អែកកោះធំ | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨<br>០១៦ ៤៧១ ៨៨៧ | | |
| ១៧ | មន្ទីរពេទ្យបង្អែកស្រុកស្អាង | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨ | | |
| ១៨ | មណ្ឌលសុខភាពព្រែកអញ្ចាញ | | ០១៧ ៥៥២ ៣២៣<br>០១២ ៨៤០ ៥២០ | | |
| ១៩ | មណ្ឌលសុខភាពវិហារសួគ៌ | ០៧៧ ៩២៦ ៦៩២ | ០១២ ៨៣២ ៣៤៣<br>០១២ ៤៩៥ ៩៨៣ | | |
| ២០ | មណ្ឌលសុខភាពសំរោងធំ | ០៩៧ ៧៩៣ ៩៩៧៤ | | | |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានីខេត្ត |
|---|---|---|---|---|---|
| ២១ | មន្ទីរពេទ្យបង្អែកប៊ុន រ៉ានី ហ៊ុន សែន វការកោង | ០១៧ ៥៥២ ៣២៣ | ០៩៧ ៩៥៣ ៩៥២៥<br>០១៧ ៥៥២ ៣២៣ | ០៩២ ៤០៧ ៨៦៨ | |
| ២២ | មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ | ០១៦ ៦៩៦ ៤៨០ | ០២៥ ៩៨៧ ៣១៣<br>០១៦ ៤៧១ ៨៨៧ | ០៩៧ ៧៨៣ ៩៣៩១ | កំពង់ស្ពឺ |
| ២៣ | មន្ទីរពេទ្យបង្អែកឧដុង្គ | ០៧៨ ៨៩១ ៩១៣<br>០១២ ៩៧៨ ៩២៥ | ០១២ ៩៧៨ ៩២៥<br>០១២ ៩១០ ០៦២ | | |
| ២៤ | មន្ទីរពេទ្យបង្អែកស្វាយរៀង | ០៤៤ ៩៤៥ ១១១ | ០១២ ៩៥៣ ៩៧៥ | ០៩៧ ៧៨៣ ៨៧៦៥ | ស្វាយរៀង |
| ២៥ | មន្ទីរពេទ្យបង្អែកជីភូ | ០១១ ៣៩៤ ១៧៨ | ០១២ ៨០៥ ២៣៦<br>០១២ ៧៦១ ០៨៩ | | |
| ២៦ | មន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង | ០២៦ ៩៨៨ ១១១ | ០១៥ ២៥០ ១១១<br>០១២ ៧០២ ២៥១ | | កំពង់ឆ្នាំង |
| ២៧ | មន្ទីរពេទ្យបង្អែកកំពង់ត្រឡាច | ០៨៥ ៥៨៧ ៧៥៧ | ០៨៥ ៥៨៧ ៧៩០<br>០១២ ៤៥៧ ៣០៨ | ០៨៨ ៩៧២ ១០១៦ | |
| ២៨ | មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ | ០១៦ ៦៨៦ ៨៤៣<br>០៨៨ ៨៦០ ០០៣៩ | ០១២ ៧១២ ៦៤៦<br>០១៦ ៧១២ ៦៤៦ | ០៨៨ ៩៧២ ១០១៤ | ព្រះសីហនុ |
| ២៩ | មន្ទីរពេទ្យ CT (ខេត្តព្រះសីហនុ) | ០៨៩ ៨៨៦ ៦៦៦<br>០៨៥ ៨៨៦ ៦៦៦ | ០៨១ ៨៨៦ ៦៦៦ | | |
| ៣០ | មណ្ឌលសុខភាពវាលរេញ | ០១៦ ៤៥២ ៧៦១ | ០១៦ ២៦៩ ៧៤៤<br>០១២ ៩៨៣ ៦១២ | | |
| ៣១ | មណ្ឌលសុខភាពអណ្តូងថ្ម | | ០១៥ ៤៥៤ ៥៦២ | | |
| ៣២ | មណ្ឌលសុខភាពរាម | | ០១៦ ៦២៥ ០១១ | | |
| ៣៣ | មន្ទីរពេទ្យបង្អែកសៀមរាប | ០១៦ ៨០០ ១១៩ | ០១២ ៩២៥ ០៦១ | ០៨៨ ៩៧២ ១០១២ | សៀមរាប |
| ៣៤ | មណ្ឌលសុខភាពពួក | ០៨៨ ៨៣៤ ៦២៥៧ | ០៩២ ៩១០ ០២៧ | | |
| ៣៥ | មន្ទីរពេទ្យបង្អែកប៉ោយប៉ែត (អូរជ្រៅ) | ០១២ ៧៨៦ ២៨៦ | ០៨៩ ៨៣៧ ៦៣៧<br>០១២ ៨៣៣ ១៥៩<br>០៩៧ ៧២៦ ៦៤៣០ | ០៨៨ ៩៧២ ១០១៣ | បន្ទាយមានជ័យ |
| ៣៦ | មន្ទីរពេទ្យបង្អែកខេត្តមិត្តភាព កម្ពុជា-ជប៉ុនមង្គលបុរី | ០១២ ៩៣២ ៥២១ | ០១២ ៩២៣ ៣៥៤<br>០៩៧ ៧៤០ ៥៤០១ | | |
| ៣៧ | មន្ទីរពេទ្យបង្អែកសិរីសោភ័ណ | ០១២ ៩១០ ៤៦៧ | ០១២ ៨៥៤ ៩៨៣ | | |
| ៣៨ | មន្ទីរពេទ្យបង្អែកស្រុកជើងព្រៃ | ០១២ ៦៦៧ ៤៨៦<br>០៨៨ ៧៧៤ ៤៧៨៨ | ០៧៧ ៩៩០ ០៤៨ | ០៩៣ ៨៧១ ០៤៣ | កំពង់ចាម |
| ៣៩ | មន្ទីរពេទ្យបង្អែកស្រុកពញាក្រែក | ០៨៨ ៧៧៤ ៤៧១១ | ០៧៧ ៩៩០ ០៤៨ | ០៩៣ ៦៦៩ ៦៣៧<br>០៧៧ ២៦០៤៦៧ | |
| ៤០ | មន្ទីរពេទ្យបង្អែកស្រុកត្បូងឃ្មុំ | ០៨៨ ៧៧៤ ៤៧០០ | ០៧៧ ៩៩០ ០៤៨ | ០៩៧ ៣៨៦ ៨៤២៣ | |
| ៤១ | មន្ទីរពេទ្យបង្អែកស្រុកមេមត់ | ០៨៨ ៧៧៤ ៤៧២២<br>០១២ ៩៦១ ៣៩៣ | ០៧៧ ៩៩០ ០៤៨ | | |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានី ខេត្ត |
|---|---|---|---|---|---|
| ៤២ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម | ០១២ ៨២៣ ៧០៩<br>០៩២ ៩៥៧ ៨៧១ | ០៧៧ ៩៩០ ០៤៨ | ០១៧ ៦២៣ ៧៦៧ | កំពង់ចាម |
| ៤៣ | មន្ទីរពេទ្យបង្អែកព្រៃកក់(ស្ទឹងត្រង់) | ០១២ ៤៩៥ ១៤៨<br>០៩២ ៣២២ ៤១៣ | ០១២ ៤៩៥ ១៤៨<br>០១១ ២៩៤ ៥៣២ | | |
| ៤៤ | មន្ទីរពេទ្យបង្អែកខេត្តក្រចេះ | ០៧២ ២១០ ៣៩១<br>០១២ ៨២២ ៣៩១ | ០១២ ៩៣១ ៨៦៨ | ០៩៧ ៧៩៧ ៨៩៩៩<br>០៩៧ ៩៨៩ ៦៦៩១ | ក្រចេះ |
| ៤៥ | មន្ទីរពេទ្យបង្អែកស្រុកឆ្លូង | ០១២ ៥០២ ៩០៣<br>០១៧ ៩០៩ ៦៥៣ | ០១២ ៣៦៧ ៧០២ | | |
| ៤៦ | មន្ទីរពេទ្យបង្អែកស្រុកស្នួល | ០៩៧ ៧៥២ ៧៩៩៦ | ០៩៧ ៨០០ ៨៥៥៥<br>០៩៧ ៦៥៩ ៧២៩៩ | | |
| ៤៧ | មន្ទីរពេទ្យបង្អែកអ្នកលឿង | ០១២ ៧៧៥ ៣១៩ | ០១២ ៦៦០ ៨១៥ | | ព្រៃវែង |
| ៤៨ | មន្ទីរពេទ្យបង្អែកព្រៃវែង | ០៩៧ ៧៨១ ៦៧៣៥<br>០៨៨ ៨៨០ ០០៧៨ | ០៩៧ ៧៩៥ ៧៤៧២<br>០១៦ ៧១២ ៨០៦ | | |
| ៤៩ | មន្ទីរពេទ្យបង្អែកពារាំង | ០៩២ ៦៥៣ ៥៩៥<br>០១២ ៦៥៣ ៥៩៥ | ០៩២ ២២៣ ៦១៤<br>០៤៣ ៦៩០ ០៩០៥ | | |
| ៥០ | មណ្ឌលសុខភាពក្តៀងរាយ | ០១២ ៦៥៨ ៣០៣ | ០១២ ៤៣៩ ៣៤៣<br>០១២ ២៩៧ ៤៩១ | | |
| ៥១ | មន្ទីរពេទ្យបង្អែកស្រុកចំចាយមារ | ០១២ ៦៩៣ ៩៤០ | ០១២ ៥៨៨ ៤៩៥<br>០៩៥ ៨៨១ ៧០៧ | | |
| ៥២ | មន្ទីរពេទ្យខេត្តតាកែវ | ០១២ ៩៣៥ ៨១៤ | ០១១ ៩០៥ ០១៩<br>០១២ ១៧២ ៨៣៤៨ | | តាកែវ |
| ៥៣ | មន្ទីរពេទ្យបង្អែកបាទី | ០១២ ៧២៤ ០៩៣<br>០៩៧ ៦៤៧ ៤៣០៣ | ០៣២ ៦៩០ ១៩៣៩ | | |
| ៥៤ | មណ្ឌលសុខភាពត្រាំខ្នារ | ០៨១ ៤៤៤ ១៧៤<br>០១២ ៤២៤ ០៦៣ | ០៩៧ ៩៥៩ ៤៦៥៣<br>០១២ ៧២៤ ០៩៣ | ០១២ ៩៤៤ ១៧៤ | |
| ៥៥ | មន្ទីរពេទ្យភ្នែកតាកែវ | | ០១៦ ៩០៤ ៨៩០ | | |
| ៥៦ | មន្ទីរពេទ្យខេត្តកែប | ០១២ ៩១២ ៣២០ | ០១២ ៨២៥ ២៧៧<br>០១២ ៤៥៦ ២៤៧ | | កែប |
| ៥៧ | មន្ទីរពេទ្យបង្អែកខេត្តកំពត | ០១២ ២៩៧ ២៦៨ | ០១២ ៣១៦ ១៣៥<br>០១២ ៩៥៥ ៩៨៦ | | កំពត |
| ៥៨ | មន្ទីរពេទ្យបង្អែកកំពង់ត្រាច | ០១២ ៧៣៣ ៤៦៨ | ០៩២ ៣៨៣ ៦៣២<br>០៨៨ ៨៧៣ ២៤៦៨ | | |
| ៥៩ | មន្ទីរពេទ្យខេត្តពោធិ៍សាត់ | ១៣៥៣<br>/០០១០ | ០១២ ៨២៨ ៤៦៦ | | ពោធិ៍សាត់ |
| ៦០ | មណ្ឌលសុខភាពឈើតុំ | ០៩២ ៣០៧ ២៧៨ | | | |
| ៦១ | មន្ទីរពេទ្យបង្អែកស្រុកក្រគរ | ០៩២ ៨១១ ១៦១ | ០៩៧ ១២២ ២៣៤៤ | | |
| ៦២ | មន្ទីរពេទ្យបង្អែកស្រុកភ្នំក្រវ៉ាញ | ០១២ ៨៥០ ៥៩០ | | | |
| ៦៣ | មន្ទីរពេទ្យបង្អែកស្រែអំបិល | ០១៦ ២២២ ១៨៦ | ០១៦ ៨៧៧ ០០៦ | | កោះកុង |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានី ខេត្ត |
|---|---|---|---|---|---|
| ៦៤ | មន្ទីរពេទ្យបង្អែកខេត្តកោះកុង | ០១៦ ៣០០ ១១៩ | ០១៦ ២០៤ ៨៨៧<br>០៩៧ ៧៩៥ ៨៧៨៨ | | កោះកុង |
| ៦៥ | មន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន | | ០៧១ ៩១៤ ៤៤១៨<br>០១៥ ៥៣២ ៣២៣<br>០៩៧ ៧៥៣ ២៣២៣ | | ប៉ៃលិន |
| ៦៦ | មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង | ០១២ ២៦៩ ៣៨៨ | ០១២ ៨៣៣ ២៦១ | | បាត់ដំបង |
| ៦៧ | មណ្ឌលសុខភាពត្រាង | ០៩៥ ២២៨ ៨៩៣<br>០៩៧ ៩១៤ ៥៨៧០ | ០១៧ ២៦៩ ៣៦៣ | | |
| ៦៨ | មណ្ឌលសុខភាពស្តៅ | ០១២ ៥៨១ ៦៥៤<br>០៩២ ២៦៤ ១៦៣ | ០១២ ៦៧០ ៩៩៦ | | |
| ៦៩ | មន្ទីរពេទ្យបង្អែកសំពៅលូន | ០១២ ៩៧៤ ២២៣<br>០៨៨ ៩១៨ ១០០៥ | ០១២ ៤៤៨ ១៩៦ | | |
| ៧០ | មន្ទីរពេទ្យបង្អែកថ្មគោល | ០៩២ ៩០៣ ៦៩៤ | ០៩២ ៧៨៦ ៣៥៦ | | |
| ៧១ | មន្ទីរពេទ្យបារាយណ៍-សន្ទុក | ០១២ ៨៦៧ ៥៧៣ | ០១៧ ៥៥៩ ៣៨៧ | | កំពង់ធំ |
| ៧២ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ | ០១៧ ៣៩៨ ៧៥០<br>០១២ ៩៤៧ ៩៣២ | ០៩២ ៩៥៤ ៣៦៧ | | |
| ៧៣ | មន្ទីរពេទ្យបង្អែកស្ទោង | ០១២ ៧៦៨ ៤៤៣<br>០១២ ៧៩៤ ៣៤៩ | ០៩២ ២៩១ ៩៥៩ | | |
| ៧៤ | មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង | ០៩២ ៧៩៩ ៤៦៤<br>០៨៨ ៨៨៤ ៩៤៨៣ | ០៩៧ ៩៧៨ ០៨៧៨<br>០១២ ៩០៨ ៥៩០ | | ស្ទឹងត្រែង |
| ៧៥ | មន្ទីរពេទ្យបង្អែកខេត្តរតនគិរី | ០១៧ ៩៣៦ ៩៤៥<br>០១២ ៨៤០ ៨០៨<br>០១៧ ៣៥៧ ៣២០ | ០១២ ៥០៥ ០០៨<br>០១២ ៥២៨ ០០៨ | | រតនគិរី |
| ៧៦ | មន្ទីរពេទ្យបង្អែកសែនមនោរម្យ | ០៩៧ ៧១២ ១៤៤៥<br>០១២ ៩៦១ ៧៤៤ | ០៩៧ ៤៧៣ ៩៦៨៥<br>០៨៨ ៩៩៨ ៦៥៦៦ | | មណ្ឌលគិរី |
| ៧៧ | មណ្ឌលសុខភាពអូររាំង | ០៩៧ ៤៧៨ ៧៧៩៧ | ០១១ ៦០៧ ៧៨៣<br>០៨៨ ៣៣២ ៩១១៨ | | |
| ៧៨ | មណ្ឌលសុខភាពកែវសីម៉ា | ០៩៧ ៦៧៨ ៨៥៣៣ | ០១២ ២៦៦ ១៥២<br>០៩៧ ៨៥០ ៤៧៦៥ | | |
| ៧៩ | មន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ | ០៩២ ១៤១ ៨៣៥<br>០១២ ៧២៣ ១២១ | ០៧៨ ២២៩ ៧៩៧<br>០៧៨ ៩៧៩ ៧២៩ | | ឧត្តរមានជ័យ |
| ៨០ | មន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង | ០៧៦ ៥២៦ ២៤៩១ | ០៧៧ ៥០៨ ០៥៧<br>០១១ ៦៧០ ១៧៤ | | |
| ៨១ | មណ្ឌលសុខភាពអូរស្មាច់ | ០១១ ៧៣៦ ៨៨៦ | | | |
| ៨២ | មន្ទីរពេទ្យបង្អែក ១៦ មករា | ០១២ ៣៧១ ៦១៨ | ០១២ ៤២៦ ៥១៩<br>០១២ ៨៩២ ៩០៩ | | ព្រះវិហារ |
| ៨៣ | មណ្ឌលសុខភាពភ្នំដែក | ០៩២ ២២៧ ៦១៦ | ០៩៧ ៣៩៤ ៤៦៦៩<br>០៩២ ៩៥៦ ៥៦៩ | | |
| ៨៤ | មណ្ឌលសុខភាពជាំក្សាន្ត | | ០១២ ៩៣៨ ១៥៩<br>០៩៧ ៧៥២ ៧៧៧៣ | | |
| ៨៥ | មណ្ឌលសុខភាពស្រអែម | | ០៩៩ ៣៥៨ ៤៤៧ | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
MINISTRY OF INFORMATION
លេខ : ១០៤ ព.មប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៤

# ប្រកាស
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខន.ស.រ.ក.ម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០/អ.ន.ក្រ.ប.ក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១/អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល និង សោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- បានឃើញប្រកាសរបស់ក្រសួងព័ត៌មានលេខ៦២៥ព.ម.ប្រ.ក ចុះថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការអនុញ្ញាតឲ្យបោះពុម្ពផ្សាយព្រឹត្តិបត្រ " បេឡាជាតិរបបសន្តិសុខសង្គម " ដោយមានលោក ជាវ ប៊ុនរិទ្ធ ជាចាងហ្វាងការផ្សាយ
- យោងលិខិតរបស់លោក ជាវ ប៊ុនរិទ្ធ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ ស្តីពីសំណើសុំបន្តអាជ្ញាបណ្ណ័បោះពុម្ពផ្សាយព្រឹត្តិបត្រ " បេឡាជាតិរបបសន្តិសុខសង្គម "។

## សម្រេច

<u>ប្រការ១</u> : អនុញ្ញាតឲ្យព្រឹត្តិបត្រ " បេឡាជាតិរបបសន្តិសុខសង្គម " បន្តអាជ្ញាបណ្ណ័បោះពុម្ពចែកផ្សាយ ដោយមានលោក ជាវ ប៊ុនរិទ្ធ ជាចាងហ្វាងការផ្សាយ ដែលមានទីស្នាក់ការស្ថិតនៅអាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

<u>ប្រការ២</u> : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារព័ត៌មាន ក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវដាក់អាស័យដ្ឋានទីចាត់ការព្រឹត្តិបត្រ ឈ្មោះចាងហ្វាងការផ្សាយ និង ឈ្មោះអាស័យដ្ឋានរោងពុម្ព នៅលើទំព័រព្រឹត្តិបត្ររបស់ខ្លួន ព្រមទាំងយកព្រឹត្តិបត្រ មួយចំនួនមកតម្កល់ទុកនៅ នាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួង ព័ត៌មាន និងចំនួន ០២ ច្បាប់ តម្កល់ទុកនៅបណ្ណាល័យជាតិ ។

<u>ប្រការ៣</u> : ក្នុងករណីប្រព្រឹត្តល្មើសដូចចែងក្នុងប្រការ១ និងប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

<u>ប្រការ៤</u> : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ០១ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ប្រការ៥</u> : អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន និងចាងហ្វាងការផ្សាយព្រឹត្តិបត្រ " បេឡាជាតិរបបសន្តិសុខសង្គម " ត្រូវអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

<u>*ចម្លងជូន*</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- គ្រប់សមាគមអ្នកសារព័ត៌មានកម្ពុជា
  " ដើម្បីជ្រាបជាព័ត៌មាន "
- សាមីខ្លួន
- ឯកសារ -កាលប្បវត្តិ